

**អ៊ុក សារិន**



# ស្រណោះព្រលឹងខ្មែរ

ដោយលោក *អ៊ិត-សារិន*
អតីតសាស្ត្រាចារ្យមធ្យមសិក្សាបឋមភូមិ
អធិការបឋមសិក្សា

បោះពុម្ពលើកទី ១
ចំនួន ៥០០០ ក្បាល

រក្សាសិទ្ធ

ជូនចំពោះវិញ្ញាណក្ខន្ធបងប្រុសខ្ញុំ
ដែលធ្លាប់បានបំរើគតិជាតិ

ព.ស. ២៥១៨

# អារម្ភកថា

គ្រោះថ្នាក់មាតុភូមិនិងសង្គមខ្មែរ មកពីបក្សសម្ពន្ធកុម្មុយនិស្តអាស៊ី មានទំហំធំធេងនិងជាក់ស្តែងពេក ពុំអនុញ្ញាតឲ្យកូនខ្មែរម្នាក់ៗ នៅព្រងើយកន្តើយ ប្រកាន់បក្សពួក ឬទាស់ទែងខ្វែងគំនិតគ្នាតទៅទៀតបានទេ។

ពេលវេលារបស់យើងម្នាក់ៗ ទាក់ទងទៅនឹងអាយុជីវិតនៃប្រទេសជាតិ និងសង្គមជាតិទាំងមូល។ ការភ័ន្តច្រឡំក្នុងទស្សនៈនយោបាយ អាចកាត់ថ្លៃជីវិតប្រទេសជាតិខ្លួនឯង ព្រោះប្រជាជាតិដ៏តូចរបស់យើងមានស្ថានភាពភូមិសាស្ត្រ និងនយោបាយស្រួយជាងប្រជាជាតិដទៃទៀត ក្នុងភូមិភាគឥណ្ឌូ-ចិននេះ ហើយប្រជាជាតិរបស់យើង ត្រូវបានកម្លាំងព្យុះនៃប្លុកកុម្មុយនិស្តអាស៊ីប្រទាញតាមរយៈយួនខាងជើង ឲ្យចូលទៅក្នុងរង្វង់លានប្រកួតរបស់គេ ដែលយើងមិនត្រឹមតែពុំអាចទាញយកផលប្រយោជន៍អ្វីសោះប៉ុណ្ណោះទេ ថែមទាំងនាំសង្គមជាតិទៅរកសេចក្តីស្លាប់សឹងចៀសមិនផុតទៀតផង ប្រសិនបើប្រទេសជាតិធ្លាក់ទៅក្នុងកណ្តាប់ដៃកុម្មុយនិស្ត។

បើប្រជាជាតិធ្លាក់ទៅក្នុងកណ្តាប់ដៃកុម្មុយនិស្ត យើងនឹងបាត់បង់ទឹកដីតែម្តង ព្រោះកម្លាំងយៀកណាមសង្គមនិយមទាំងពីររួមគ្នា (បើកុម្មុយនិស្តលេបខ្មែរបានហើយ តើយៀកណាមខាងត្បូងអាចទប់ទល់នឹងកុម្មុយនិស្តតទៅទៀតបានដែរឬទេ?) អាចលេបទឹកដីខ្មែរដោយមិនបាច់ទំពារ។

សព្វថ្ងៃនេះ គ្មានគំនិតចក្រពត្តិនិយម និងគំនិតរាតត្បាតទឹកដីនិយម (Expansionnisme) បែបថ្មីណាមួយមានសម្ផស្សស្នេហ៍នឹងកម្លាំងស្រូប (Force d'attraction) ជាជាងគំនិតបញ្ឆេះភ្លើងសង្គ្រាមបដិវត្តន៍សង្គមនិយមនេះទេ។ តាមរយៈទ្រឹស្តី «ម៉ាក្សិស្ត ឡេនីនិស្ត» យួនយៀកកុង-យៀកណាមខាងជើង ដែលនៅមានគំនិតជាតិនិយមខ្លាំងនៅឡើយ ឈានមកលេបទឹកដីឥណ្ឌូចិនទាំងមូល សមនឹងជាតិយួនជាពូជសាសន៍ខ្លាំង ខ្លាត ពូកែជាងយើងទៀតផង។

តើបក្សកុម្មុយនិស្តខ្មែរ អាចមានអ្វីអះអាងបានចំពោះគ្រោះថ្នាក់នេះ? តើបក្សកុម្មុយនិស្តខ្មែរអាចឲ្យទ័ពត្រួតត្រា (Force d'occupation) របស់យួនខាងជើងដកថយពីទឹកដីខ្មែរបានទេ?

បើខ្មែរធ្លាក់ទៅក្នុងកណ្តាប់ដៃកុម្មុយនិស្ត «សង្គមខ្មែរថ្មី» នឹងអស់ខ្លឹមសារជាតិ (Essence nationale) អស់គោលចរិតជាតិ (Entité nationale) ។ សង្គមខ្មែរថ្មីត្រូវប្រែក្លាយទៅតាម «សង្គមម៉ាក្សិស្ត»។

បើអស់ខ្លឹមសារជាតិហើយ (មានព្រះពុទ្ធសាសនាជាអាទិ៍) សង្គមខ្មែរច្បាស់ជារលាយចូលទៅក្នុងសង្គមជាតិយួនដោយមិនដឹងខ្លួន ព្រោះកម្លាំងស្រូបពីសំណាក់សង្គមយួន ត្រូវតែគ្របសង្កត់ទប់មិនឈ្នះមកលើសង្គមខ្មែរ។ នេះហើយជាជង្ហើមចុងក្រោយនៃជីវិតខ្មែរ !!!

គឺក្នុងគោលបំណងជួយបំភ្លឺគោលដៅខ្លះៗ នៅក្នុងផ្ទៃក្នុងបញ្ហាខ្មែរ និងចង់ចុះបង្ហាញនូវគ្រោះថ្នាក់ធំៗ លេចចេញមកពីពួកកុម្មុយនិស្តនៅក្នុងប្រទេស ទើបខ្ញុំប្រឹងប្រយ័ត្នបើកកកាយនូវអនុស្សាវរីយ៍ផ្ទាល់ខ្លួនដែលខ្ញុំបានជួបប្រទះ បានហែលឆ្លងខ្លួនឯងនៅក្នុងជួរខ្មែរក្រហម ក្នុងរយៈពេល ៩ ខែ។

តាមពិត កូនសៀវភៅតូចនេះគ្រាន់តែជាកម្រងអនុស្សាវរីយ៍ (Album de souvenirs) ផ្ទាល់ខ្លួនមួយតូចប៉ុណ្ណោះ ឬជាកម្រងឯកសារពីតំបន់ខ្មែរក្រហម។

សូមឲ្យកូនឯកសារនេះ បានក្លាយទៅជាវិភាគទានដ៏ស្ដួចស្ដើងមួយ ក្នុងការបង្រួបបង្រួមរវាងខ្មែរនិងខ្មែរ ក្នុងកាលៈទេសៈបច្ចុប្បន្ននេះ។

ធ្វើនៅភ្នំពេញ, ថ្ងៃទី ២៨ កក្កដា ១៩៧៣

អ.ស.

«««««★★★★»»»»»

# ដំណើរឆ្លងកាត់តំបន់ខ្មែរក្រហម

*<u>ថ្ងៃ ១៧-១៨ មេសា ១៩៧២</u>*

*យើងបានទទួលទានដំណេកនៅក្នុងខ្ទមចំការដែលគេបានបោះបង់ចោល។ មេកងឈ្លប «រណសិរ្ស» ជាអ្នកទទួលខុសត្រូវលើសន្តិសុខនិងដំណើរយើងខ្ញុំ បានយកសំពត់កៅស៊ូពីរផ្ទាំងឲ្យយើងក្រាលលើដីធ្វើជាកន្ទេល។ រាត្រីស្ងាត់ជ្រងំ អំពិលអំពែកហើរព្រោងព្រាតឃើញកូនពន្លឺភ្លឹបភ្លែតៗ។ មេកងឈ្លបសុំឆែកកាបូបយើងក្រែងមានអាវុធ ឬវិទ្យុក្នុងនោះ។ គេស្នើសុំកុំជក់បារីក្រែង «ខ្មាំង» មើលឃើញ។ នៅជុំវិញយើង កងឈ្លប ៦ ឬ ៧ នាក់ផ្លាស់វេនគ្នាយាម។*

*ព្រឹកឡើង ថ្ងៃ ១៨ មេសា វេលាម៉ោង ៥ កងឈ្លបជូនដំណើរយើងទៅកាន់ភូមិមួយទៀត នៅចំងាយប្រមាណ ៧ ឬ ៨ គ.ម. ពីស្រុកកន្ទួតក្នុងខេត្តកណ្ដាល។ ភ្លៀងដើមឆ្នាំធ្លាក់ជោកជាំរហូត។ ដល់ភូមិ យើងបានជួបប្រទះកងឈ្លបមួយក្រុមទៀត មានពីរនាក់កំពុងបរិភោគអាហារ។ យើងបានស្វាគមន៍ «ភាតរភាពបដិវត្តន៍» ជាមួយកងឈ្លបទាំងនោះ ហើយពួកគេបានហៅយើងឲ្យចូលរួមអាហារជាមួយពួកគេ តែពួកគេសម្លឹងយើងដោយយកចិត្តទុកដាក់ ដូចមានអាការៈចម្លែកអ្វីម្យ៉ាងនៅក្នុងខ្លួនយើង ប្រ-ហែលជាគេមិនពេញចិត្តនឹងរបៀបស្លៀកពាក់ ឬអាកប្បកិរិយារបស់យើងក៏មិនដឹង។ គេមិនសូវជេញដោលយើងទេ។ ចំណែកយើងវិញ យើងក៏រក្សា «លក្ខណ៍ការសម្ងាត់» មិនហ៊ានជេញដោលសួរគេវិញដែរ សូម្បីតែឈ្មោះភូមិក៏យើងមិនហ៊ានស្នើសួរ ព្រោះ «ស្នងការនយោបាយ» ធ្វើការបង្កប់ខ្លួននៅទីក្រុងភ្នំពេញម្នាក់ដែលជូនដំណើរយើង បានក្រើនរំលឹកកុំឲ្យយើងបង្ហើបប្រាប់ឈ្មោះពិតប្រាកដ ឬមុខងាររបស់យើងឲ្យនរណាដឹងឲ្យសោះ។ យើងបានជួបស្នងការនយោបាយក្រុងនេះ នៅរាត្រីថ្ងៃទី ១៧ មេសា ១៩៧២ តែយើងពុំស្គាល់ឈ្មោះ ឬមុខងារដើមរបស់ <មិត្ត> នេះទេ។ រឿងរក្សាការសម្ងាត់គ្រប់ទីកន្លែង និងគ្រប់កាលៈទេសៈជាវិន័យទី ១ របស់អង្គការខ្មែរក្រហមដែលយើងបានទទួលតាមផ្លូវ។*

*នៅម៉ោង ៨ កន្ទះយប់ យើងបានចូលមកដល់ភូមិមួយទៀត ដោយដើរតាមភ្លឺស្រែខ្ពស់ៗ សំបូរទៅដោយដើមត្នោតនិងដើមសង្កែ។ អ្នកស្រុកម្នាក់នៅក្នុងភូមិនេះ បានជូនដំណើរយើងបន្តទៅមុខទៀត។ ក្រុមរួមដំណើររបស់យើងកើនបានគ្នា ៧ នាក់។ យើងពុំដឹងថាគេមានបំណងនាំយើងទៅដល់ណា? ទំព័រផ្សងព្រេងមួយបែបថ្មីរបស់យើង បានបើកឡើងមិនខុសពីពាក្យពោលថា «ដើរទៅចូលរូងខ្លា» ទេ តែយើងមានជំនឿខ្លះៗ ទៅលើសមត្ថភាពដោះកុនរបស់យើង និងទៅលើសន្ដានចិត្តជ្រះថ្លាផ្ទាល់ខ្លួនក្នុងបញ្ហាជាតិ។*

*បន្ទាប់ពីយើងមានការឈឺចាប់នឹងអំពើឈ្លានពានរបស់យៀកកុង និងយៀកណាមខាងជើងមកលើទឹកដីខ្មែរមក យើងរឹតតែមានការឈឺចាប់ពើតខ្លាំងណាស់ទៅទៀត ក្នុងរឿងឃុបឃិតរបស់ខ្មែរក្រហមជាមួយយៀកកុង-យៀកណាមខាងជើង។*

*ដល់ពាក់កណ្តាលអធ្រាត្រ យើងបានមកដល់ផ្សារស្គន់-ទន្លេបាទី ហេវហត់រសេះរសោះដៃជើង ព្រោះគឺជាលើកទី ១ ដែលយើងធ្វើដំណើរដោយជើងចំនួន ៦-៧ ម៉ោង។ ប្រធានវណសិរ្សនៅផ្សារស្គន់ រៀបចំឲ្យយើងសំរាកនៅផ្ទះទៀមចិនមួយ ដែលម្ចាស់បានបោះបង់ចោល។ យប់នោះយើងបានទទួលទានដំណេកលក់ស្កប់ស្កល់។*

*ថ្ងៃ ១៩-២០ មេសា :*

*ព្រឹកឡើង ការចាប់អារម្មណ៍ដំបូងរបស់យើង គឺសភាពស្ងាត់ជ្រងំរបស់ទីប្រជុំជននេះ។ ផ្ទះធំៗទៀមចិនជាច្រើនបិទទ្វារចោល។ មានគ្រួសារ ៧-៨ គ្រួសារប៉ុណ្ណោះដែលក្រាញនៅទីនេះ។ ប្រធានវណសិរ្សជាកូនចៅចិនមាឌជំបង រូបរាងស្អាត បុកពារសង្ហាបីតបារីស្ទឹកសង្កែធ្វើវាហឺ។ យើងឆ្ងល់ថាហេតុអ្វីក៏មិត្តនេះមិនរត់ទៅនៅរកស៊ីឯផ្សារកន្ទួត ឬភ្នំពេញ, បែរជានៅឃុបឃិតនឹងខ្មែរក្រហមយៀកកុងយៀកណាមខាងជើងឯណោះទៅវិញ? ឬមួយក៏ក្រាញចាំធ្មៀតធ្វើឈ្មួញកណ្តាលរកស៊ីជាមួយ «អង្គការ» ទេដឹង? ។*

*ម៉ោងប្រមាណ ៦ កន្លះព្រឹក គេហៅយើងទៅបរិភោគបាយនៅលើផ្ទះធំមួយដែលម្ចាស់បោះបង់ចោល។ នៅទីនោះយើងបានជួបប្រទះ និងសំដែងការគួរសមជាមួយមិត្តមេបញ្ជាការ «កងវរៈ» (កងអនុសេនាធំ) មេបញ្ជាការកងវរសេនាតូច និង មិត្តស្នងការនយោបាយពីរនាក់ទៀត។ មិត្តទាំងអស់នោះសម្តែងទឹកចិត្តសោមនស្សរីករាយ ចំពោះវត្តមានរបស់យើងនៅក្នុងជួររបស់គេ។ មានស្នងការនយោ-បាយម្នាក់ ជាអតីតគ្រូបង្រៀន បានហុចបារីសញ្ញាស៊ីកមាសមកខ្ញុំមួយដើម ហើយសួរសុខទុក្ខរបស់យើងនៅតាមផ្លូវ។ យើងក៏សំដែងអំណរគុណតបតទៅគេវិញ ហើយរង់ចាំសំនួរដទៃទៀត តែមិត្តនោះបែរជានិយាយពីជីវប្រវត្តិខ្លះៗ របស់គេប្រាប់ខ្ញុំទៅវិញ គឺគេជាអតីតគ្រូបង្រៀន «ជាប់នឹងចលនាបដិ-វត្តន៍» នេះជាយូរមកហើយ។ ក្រោយព្រឹត្តិការណ៍ ១៨ មិនា ១៩៧០ គេរត់មករួមកម្លាំងនៅក្នុងព្រៃ ព្រោះមិត្តនោះធ្លាប់ «បែកមុខបែកមាត់» (ភាសារបស់គេមានន័យថា៖ បែកការណ៍សម្ងាត់) ម្តងរួចមកហើយ។ មិត្តនោះបានប្រាប់មកយើងទៀតថា ប្អូនប្រុសរបស់គេម្នាក់ទៀត ជាសាស្ត្រាចារ្យមធ្យមសិក្សាបឋមភូមិឈ្មោះ ស.ត.ឆ បានរត់ចូលមករួមកម្លាំងបដិវត្តន៍របស់គេចំនួន ៤ ខែមុននេះដែរ។*

*មិត្តម្នាក់ទៀត ប្រហែលជាស្នងការនយោបាយ «កងវរៈ» បានពិភាក្សាជាមួយយើងពីបញ្ហា «ស្តេចសីហនុ»។ មិត្តនោះប្រហែលជាយល់ថា យើងពិតជា «ស្ងួល» ខ្មែរក្រហមធ្វើការនៅក្រុងភ្នំពេញ ធ្លាប់ «ជាប់ចលនាតស៊ូ» របស់គេតាំងពីជំនាន់ស្តេចសីហនុ បានជាមិត្តនោះថ្លោយសំដីថា៖ "អង្គការមិនឲ្យសីហនុមកស្រុកខ្មែរក្នុងពេលឥឡូវនេះទេ ព្រោះបើឲ្យសីហនុមក ច្បាស់ជាប្រជាជនរត់ទៅរកសីហនុហើយ ចំណែកយើងវិញ យើងពិតជាបោសគូទទទេ។*

*ពុសំដីនេះភ្ញាមខ្ញុំភ្ញាក់ព្រើត ព្រោះដំបូងខ្ញុំគ្រាន់តែសង្ស័យថា ខ្មែរក្រហមនិងស្តេចសីហនុ ម្តេចទៅជាត្រូវរ៉ូវនឹងគ្នាទៅរួច បើម្ខាងជាកុម្មុយនិស្ត ម្ខាងទៀតជាស្តេចជាសក្តិភូមិ។ នៅមានចំណុចជាច្រើនទៀតដែលយើងនៅស្រពិចស្រពិល តែយើងមិនហ៊ានបង្កើបសួរ គឺចំណុចទាក់ទងនឹងវណសិរ្សនិងរដ្ឋាភិបាលរួបរួមជាតិកម្ពុជា និងយៀកកុង-យៀកណាមខាងជើង។*

ព្រោះតែយើងចង់ដឹងពីការពិតនៅក្នុងបញ្ហាខ្មែរ និងព្រោះតែឈឺចាប់នឹងរឿងខ្មែរក្រហមចូលហ៊ុននឹងយៀកកុង-យៀកណាមខាងជើង ក្នុងការកាប់សម្លាប់ខ្មែរគ្នាឯង ទើបយើងប្រថុយខ្លួនធ្វើមមាចដើរចូលភ្លើង ដោយមានអាវុធម្យ៉ាង គឺឆន្ទៈសម្របសម្រួលខ្លួនឯងទៅតាមស្ថានភាព និងឆន្ទៈស្រឡាញ់អ្វីដែលជាខ្មែរ ដូចដែលលោក ឈូក-ម៉េងម៉ៅ, វរជន «ខ្មែរកណ្ដាល» ស្អាតស្អំមួយរូប, ធ្លាប់ស្រក់ទឹកភ្នែកពេលលោករំលឹកពី «ព្រលឹងខ្មែរ» ម្ដងៗ... ។

កាលដឹងយើងឃើញមិត្តថ្ងោះធ្លោយហ៊ាននិយាយពី «បញ្ហាសីហនុ» នៅចំពោះមុខខ្ញុំ មិត្តស្នងការក្រុងភ្នំពេញក៏ហៅមិត្តនោះទៅខ្សឹបស្ងាត់ៗ ប្រហែលជាគេហាមប្រាមមិនឲ្យនិយាយរឿងនេះតទៅទៀត ឬគេខ្សឹបប្រាប់គ្នាគេថាមិនមែន «ស្នូល» ខ្មែរក្រហមក៏មិនដឹង។

នៅម៉ោង ៤ រសៀល មានមនុស្សពីរនាក់ យកកងមកបញ្ជិះយើងទៅកាន់ភូមិខ្នារត្បែង ចម្ងាយប្រមាណ ១ គ.ម. កន្លះ ពីផ្សារស្គន់។ នៅតាមផ្លូវ យន្តហោះ តេ-២៨ ពីរគ្រឿងទើបវិលមកពីទំលាក់គ្រាប់បែក។

ភូមិខ្នារត្បែងក៏មានសភាពស្ងាត់ជ្រងំ យូរៗម្ដង គេជួបប្រទះអ្នកស្រុកម្នាក់ៗ ផ្ទះក្បឿងជាច្រើនត្រូវគេបោះបង់ចោល និងត្រូវគ្រាប់បែកធ្លុះធ្លាយដំបូល ជញ្ជាំងៗ នៅក្រោមផ្ទះពីរខ្នង កងទ័ពខ្មែរក្រហមមួយក្រុម មានគ្នាប្រមាណ ៥០ នាក់កំពុងរៀបចំបរិភោគបាយ ជាមួយនឹងយុវនារី ៤ នាក់ ដែលយើងសន្និដ្ឋានថាជាពេទ្យសម្រាប់កងទ័ព។

កងទ័ពនេះជាកងទ័ពប្រចាំតំបន់ ១៥, មិត្តមេបញ្ជាការទទួលយើងដោយរាក់ទាក់ គេយកនំនិងឪឡឹកទុំមកឲ្យយើងបរិភោគ រួចក៏សាកសួរយើងពីស្ថានភាពនៅភ្នំពេញ ពីនាយទាហានសាធារណរដ្ឋពីអាមេរិកាំងៗ ចំឡើយរបស់យើង ថាគ្មានកងទ័ពអាមេរិកាំងនៅភ្នំពេញទេ ហាក់ដូចជាធ្វើឲ្យគេមិនជឿនិងមិនពេញចិត្តសោះ។ គេឆ្លៀតឱកាសកំពុងសន្ទនាគ្នាដើម្បីបំផុសកំហឹងរបស់គេ កំហឹងបដិវត្តន៍ចំ-ពោះរបបសាធារណរដ្ឋយើងៗ គេចោទថាជា «ខ្ញុំបំរើអាមេរិកាំង ជាចក្រពត្តិ ជាពួកមូលធននិយមយោធានិយមហ្វាស៊ិស ជិះជាន់សង្កត់សង្កិន»។ ឃើញយើងនៅស្ងៀមធ្វើមុខស្មើ មិត្តនោះផ្អាកធម៌ទេសនារបស់គេ។

<u>ថ្ងៃ ២០ មេសា</u> :

ព្រឹកឡើង មិត្ត <នីរសា> ម្នាក់ទៀតទទួលភារៈជូនដំណើរយើងទៅទៀត។ យើងភ្លេចជំរាបថាមិត្តស្នងការនយោបាយជំក្រុងភ្នំពេញ ដែលជូនដំណើរយើងមកដល់ស្គន់-ទន្លេបាទី ត្រូវបានវិលត្រ-ឡប់ចូលក្រុងភ្នំពេញវិញ។ ពីខ្នារត្បែងតទៅ យើងមានកំព្វាសនាបានជិះម៉ូតូហុងដាម្ដងៗ យើងបានឆ្លងកាត់ភូមិតូចៗ ជាច្រើន ហើយសរសៀតាមផ្លូវរថភ្លើងភ្នំពេញ-កំពត។ មិត្តនីរសាបានប្រាប់យើងថាយើងចូលក្នុងដែនដីខេត្តតាកែវហើយ។ ភូមិនានាចាប់មានជីវិតអ៊ូអរជាធម្មតា។ នៅតាមផ្លូវ យើងជួបប្រទះលេណដ្ឋានជាហូរហែ ប្រជាកសិករប្រកបការងារដូចប្រក្រតី ការលក់ដូរទំនិញចំណីបន្តិចបន្តួចមានចប់តាមផ្លូវ។ នៅម៉ោង ១១ យើងបានឆ្លងផ្លូវជាតិលេខ ៣ ក្បែរផ្លូវលំឆ្ពោះទៅស្រុកបរសែត។ ផ្ទះថ្មជាច្រើនខ្នងនៅអមផ្លូវជាតិ ត្រូវបាក់បែកខូចអស់ នៅសល់តែគំនរអិដ្ឋរបាំងរបោយ។ ថ្នល់ជាតិត្រូវជីកគាស់ កាត់ផ្ដាច់ដោយអន្លើ។

យើងបានមកឈប់សំរាកនៅមុខវត្តមួយនៅខាងត្បូងថ្នល់ជាតិ ចំងាយប្រហែល ២ គ.ម ។ នៅទីនោះ មានរទេះបងប្អូនអ្នកស្រុកជាច្រើន ដែលរត់គៀសខ្លួន ឬពួកខ្មែរក្រហមជន្លៀសមកដល់ទីនេះ។ បន្តិចក្រោយមក មានឡានហ្ស៊ីប ខ្មែរក្រហមមួយគ្រឿងចងស្ទឹកឈើ បើកមកឈប់នៅក្នុងវត្ត។ នៅក្នុងសាលារៀន និងនៅក្រោមកុដិលោក យើងប្រទះឃើញកងទ័ពខ្មែរក្រហមឬខ្មែររណសិរ្សដេកលើអង្រឹងនីឡុងព្រោងព្រាតដូចហ្វូងប្រចៀវ។

នៅម៉ោង ១២ ថ្ងៃត្រង់ យើងបានមកដល់ទីរួមផ្សារបរសែត។ ទៀមចិនលក់អីវ៉ាន់ ៥-៦ នៅបើកទ្វារស្ងាត់ជ្រងំ។ មិត្តនីរសាបាននាំយើងទៅជួបប្រធានតំបន់ដែលជាអតីតគ្រូបង្រៀនធ្លាប់ធ្វើការនៅសាលាបឋមសិក្សាសន្ទរម៉ុក ហើយដែលបានចេញទៅនៅព្រៃតាំងពីឆ្នាំ ១៩៦៦។ យើងពុំអាចស្រាវជ្រាវរកឈ្មោះដើមឃើញទេ យើងគ្រាន់តែស្គាល់ឈ្មោះបដិវត្តន៍របស់គេប៉ុណ្ណោះ (ឈ្មោះ ហំ)។ មិត្ត ហំ ក្រោយពីបានអានលិខិតរបស់មិត្តស្នងការនយោបាយក្រុងភ្នំពេញហើយ ក៏ចាប់ផ្ដើមសួរពត៌មានយើងពីឈ្មោះពិតប្រាកដរបស់យើង ពីអាជីវកម្មនៅក្នុងសង្គមចាស់ (នេះជាសំដីរបស់គេ) ពីស្រុកកំណើត ពីទីកន្លែងធ្វើការ។ បន្ទាប់មកក៏ចាក់ទឹកតែហុចមកឲ្យយើង ព្រមទាំងនាំយើងទៅស្រស់ស្រូបបបរសនឹងត្រីងៀត។ គឺមិត្ត ហំ នេះហើយដែលជាអ្នកត្រួតត្រាតំបន់ដង្កោស្រុកកណ្ដាលស្ទឹង មានឡានអ៊ីស៊ុយហ្ស៊ីយមួយ និងម៉ូតូហុងដាជាច្រើនសំរាប់ប្រើការ។ គឺជាបុរសមាឌទាប មាំ កំពស់ប្រមាណ ១,៥៨ ម. មិនសូវនិយាយស្ដី មានអាយុប្រមាណ ៤០ ឆ្នាំ។

នៅម៉ោង ២ រសៀល មិត្តនីរសាដែលបានជូនដំណើរ បានបន្តទៅមុខទៀត។ មិត្ត ហំ បានសរសេរកូនសំបុត្រមួយឲ្យយើងកាន់ ហើយប្រាប់ថាយកលិខិតនេះទៅប្រគល់ឲ្យមិត្តហង់ (ឈ្មោះបដិវត្តន៍) នៅមន្ទីរ ៣០៥ ផ្ទាល់ដៃ។ យើងធ្វើដំណើរកាត់តាមភូមិកាត់ភ្លុក-ក្រសាំង មកដល់ភូមិវាលល្បៀងក្នុងសង្កាត់ផុង ក្នុងខេត្តកំពង់ស្ពឺ។ មិត្តនីរសាបានណែនាំយើងឲ្យប្រើពាក្យ «ហូប» ជំនួសពាក្យបរិភោគ ឬញ៉ាំ ហើយឲ្យទំលាប់ប្រើពាក្យ «មិត្ត» ដូចគេដូចឯង។ មកទល់នឹងថ្ងៃនេះ យើងបានជួបយៀកកុងតែ ២ នាក់ប៉ុណ្ណោះ ដែលកំពុងអង្គុយស៊ីគុយទាវនៅភូមិក្រសាំង-កាត់ភ្លុក។

មកដល់ភូមិវាលល្បៀង មិត្តនីរសា, បន្ទាប់ពីបានប្រគល់យើងនិងលិខិតមិត្ត ហំ ឲ្យអនុប្រធាន «មន្ទីរនីរសា» នៃភូមិភាគពិសេសហើយ, ក៏វិលត្រឡប់ក្រោយវិញ។ មិត្ត មាំង (ឈ្មោះបដិវត្តន៍) ជាអនុប្រធានមន្ទីរនីរសា នាំយើងទៅសំរាកនៅក្នុងផ្ទះអ្នកស្រុកមួយខ្នង ដែលគេយកធ្វើជាឃ្លាំងផ្ទុកឥវ៉ាន់ មានសំពត់ ប្រេងកាត អំបិល សំពត់កៅស៊ូ ជាដើម។ មន្ទីរឬក្រុមនេះមានភារៈសំរាប់ចាត់ចែងដឹកជញ្ជូនឥវ៉ាន់ពីតំបន់ស្អាងកោះធំ (តំបន់ ២៥) ឬ ពីស្ពានទន្លេបាទី យកទៅភូមិភាគពិសេស ដោយឆ្លងកាត់តាមផ្លូវលេខ ៤។ មានឡានធំ ៣ ដែលសុទ្ធជាឡានរត់ឈ្នួល (ឡានរត់ឈ្នួលធំមួយមានដាក់យីហោ ហុក-ហេង) ម៉ូតូហុងដា ៣ គ្រឿងនិងទោចក្រយាន ៤ ឬ ៥ ទៀត ព្រមទាំងដរិ ៣ ក្បាលទុកសំរាប់ឲ្យក្រុមនីរសាប្រើប្រាស់ក្នុងការដឹកជញ្ជូនឥវ៉ាន់។

<u>ថ្ងៃ ២០ មេសាដល់ថ្ងៃ១២ ឧសភា ១៩៧២ :</u>

នៅថ្ងៃដំបូង ប្រជាកសិករនៅក្នុងភូមិវាលល្បៀង ទទួលអបអរសាទរនឹងយើងខ្លាំងណាស់។ គណៈកម្មការរណសិរ្សភូមិបាននាំគ្នារៀបចំបាយទឹកម្ហូបចំណីទទួលយើង ព្រមទាំងរៀបចំរាត្រីសិល្បៈ

*តូចមួយដែលសំដែងដោយកុមារា-កុមារីនៅក្នុងភូមិ ជូនជាកិត្តិយសដល់យើងទៀតផង។ គឺជាថ្ងៃដំបូងដែលយើងបានឃើញទិដ្ឋភាពនៃចំរៀង និងរបាំអង្គការបដិវត្តន៍ខ្មែរក្រហម។ យើងមានក្តីរំភើបនិងសោមនស្សជាខ្លាំងចំពោះមេត្រីភាព និងការយកចិត្តទុកដាក់របស់បងប្អូនប្រជាកសិករ ហើយយើងក៏បានថ្លែងអំណរគុណដោយទឹកចិត្តស្វាមីភក្តិនិងមេត្រីភាពតបតទៅរកបងប្អូនទាំងអស់នោះវិញ។ ការយកចិត្តទុកដាក់របស់បងប្អូនប្រជាកសិករមកលើរូបយើង ហាក់ធ្វើឲ្យមិត្តមាំងនិងសហការីគេច្រណែននឹងយើងខ្លះៗ ដែរ។*

*ប្រជាកសិករនៅភូមិវាលល្មៀង មានជីវភាពក្រខ្សត់ខ្លាំងណាស់ ម្ហូបចំណី ត្រីសាច់ពុំមានគ្រប់គ្រាន់ទេ។ បងប្អូនទាំងនោះជំពាក់ចិត្តទៅលើ «សម្តេចឪ» យ៉ាងជ្រៅ។ មានចាស់ទុំជាច្រើននិយាយសរសើរពី «សម្តេចឪ» ហើយត្អូញត្អែរថា, “សព្វថ្ងៃនេះ វាស្រ្តរងារណាស់ រងាដូចកូនមាន់បាត់មេ” (បាត់សម្តេចសីហនុ)...។ ប្រជាកសិករនៅតែសង្ឃឹមថា សម្តេចសីហនុនឹងវិលមកកាន់អំណាចវិញនៅពេលណាដែលកងទ័ពរណសិរ្សវាយយកភ្នំពេញបាន។*

*ចំណែក មិត្ត មាំង និង មិត្ត ចាន់ ប្រធានមន្ទីរនីរសានេះវិញ សុទ្ធតែជាក្របខ័ណ្ឌកុម្មុយនិស្ត។ គេនាំគ្នាលាក់បំបិទការពិតមិនទាន់ឲ្យប្រជាកសិករនៅក្នុងតំបន់នេះដឹងទេ។ នេះជាយុទ្ធវិធីប្រមូលកម្លាំងមួយរបស់អង្គការខ្មែរក្រហម។*

*ថ្ងៃបន្ទាប់មក ដូនចាស់ម្នាក់ឈ្មោះយាយ ម៉ែន បាននាំយើងទៅនៅផ្ទះថ្មីមួយខ្នងទៀតដែលទើបនឹងសង់ហើយ។ យើងបានទទួលការឧបត្ថម្ភយ៉ាងកក់ក្តៅពីសំណាក់ដូនចាស់នេះ និងញាតិមិត្តចាស់ទុំជិតខាងដទៃទៀត។ សឹងតែរាល់ថ្ងៃ ញាតិមិត្តជិតខាងយកនំចំណី ថ្នាំជក់ ដូងខ្ចី ស្លឹកសង្កែ មកឲ្យយើង ហើយនៅពេលល្ងាចៗ បងប្អូនទាំងនោះតែងនាំគ្នាមកសួរសុខទុក្ខជាមួយយើង បង្កើតជាចំណងមេត្រីភាព និងការយល់គ្នាទៅវិញទៅមករឹតតែជិតស្និទ្ធថែមទៀត។*

*មានពេលខ្លះ យើងនឹករលឹកមកកូនប្រពន្ធ គ្រួសារញាតិមិត្តយ៉ាងលន្វង់លន្វោច ជាហេតុធ្វើឲ្យយើងរឹតតែពើតខ្លាំងឡើងទៀតនឹងសង្គ្រាមនេះ, សង្គ្រាមដែលធ្វើឲ្យយើងបែកបាក់គ្នា សង្គ្រាមដែលសាបព្រួសនូវទុក្ខវេទនាសព្វយ៉ាង ដល់ប្រជារាស្រ្តស្លូតត្រង់។ ពេលជួបប្រទះយៀកកុងតាមផ្លូវម្តងៗ យើងសឹងតែលោតទៅច្របាច់ក កាប់ចិញ្ច្រាំឲ្យអស់ចិត្ត!!!*

*ការស្នាក់អាស្រ័យនៅក្នុងភូមិវាលល្មៀងជាយូរថ្ងៃ កាន់តែធ្វើឲ្យយើងអផ្សុកតប់ប្រមល់ខ្លាំងឡើងៗ ។*

*នៅថ្ងៃទី ៦ ឧសភា, មិត្ត ចាន់ (ឈ្មោះបដិវត្តន៍) បាននាំមិត្ត នង-សួន ហៅ ចំរើនជ័យ ទៅសាកសួរសុខទុក្ខយើង ដោយមានយុទ្ធជនខ្មែរក្រហមចំនួន ៥ នាក់អមការពារសន្តិសុខផង។ នង-សួន ជាស្នងការនយោបាយតំបន់ ២៥ (ស្រុកស្អាងកោះធំ) ឬគេហៅថា «លេខាតំបន់ ២៥» (លេខាធិការបក្សនៅក្នុងតំបន់) ។*

*នៅក្នុងការសន្ទនាជាមួយ នង-សួន ខ្ញុំឆ្លៀតឱកាសសរសើរនូវវីរភាពនិងស្មារតីរឹងប៉ឹងរបស់ នង-សួន ក្នុងការធ្វើបដិវត្តន៍ នូវសេចក្តីក្លាហានរបស់ នង-សួន នាសមាជពិសេសនៅវាលមេរុ ដែលនាំឲ្យ នង-សួន ជាប់គុករហូតមកដល់ឆ្នាំ ១៩៧០។ នៅល្ងាចថ្ងៃដដែល បងប្អូននៅក្នុងភូមិបានរៀបចំម្ហូបចំណីជប់លៀងឲ្យ «សមមិត្ត» នង-សួន និងយើងទាំងអស់គ្នា, មិត្ត ចាន់ ប្រធានមន្ទីរដឹកនាំបាន*

ប្រាប់យើងថា, "ប្រហែលជា ៤-៥ ថ្ងៃទៀត មិត្តនឹងបានចេញដំណើរទៅ «អង្គការលើ» ។ ខ្ញុំបានវាយទូរលេខទៅជំរាបអង្គការលើពីរឿងមិត្តរួចហើយ" ។

ខ្ញុំភ្ញាក់ព្រើតកាលបើឮមិត្តចាន់ប្រាប់ថា, «មានវាយទូរលេខ» ព្រោះខ្ញុំមិនបានចាប់ភ្លឹកថា អង្គការខ្មែរក្រហមគេយកចិត្តទុកដាក់នឹងខ្ញុំដល់ថ្នាក់នេះ។

នៅថ្ងៃបន្តបន្ទាប់មកទៀត យើងចាប់ផ្ដើមជួបយៀកកុងយៀកណាមខាងជើងឆ្លងកាត់ភូមិជាញឹកញាប់ មានដឹកអង្ករ បន្លែ មាន់ទា និងដឹកគ្រាប់កាំភ្លើងត្បាល់តាមកង់។ ជួនកាលមានឃើញពួកវាមិនដែលដើរកាត់ភូមិទេ មានតែក្រុមសេដ្ឋកិច្ច ជាអ្នកដើរចេញចូលរកទិញស្បៀងតាមភូមិ។

ពេលឃើញជនបរទេសសត្រូវឈ្លានពាន យើងក៏នឹកឃើញដល់វាសនាស្រុកទេស ដល់ឯករាជ្យរបស់ប្រជាជាតិ ដល់វិនាសកម្មរបស់ប្រជារាស្ត្រចំនួន ៧ ឆ្នាំកន្លងមកហើយ ។ល។

ចុះខ្មែរក្រហម?... នេះហើយជាចំណោទ!!!

ថ្ងៃទី ៧ និង ៨ ឧសភា មិត្តចាន់បានជូនដំណើរ នង-សួន ឡើងទៅលើ (អង្គការលើ)។ ថ្ងៃ ៨ និង ៩ ឧសភា ភ្លៀងបង្អុរខ្លាំងលាយនិងខ្យល់ព្យុះធំ ទឹកដក់សសាចពាសពេញស្រែ។ អារម្មណ៍របស់យើងវិលវល់នឹកដល់ការសប្បាយ និងសេចក្ដីសុខសាន្តនៅក្រោមដំបូលគ្រួសារដ៏កក់ក្ដៅ ដែលយើងធ្លាប់ជួបប្រទះពីដើមរៀងមក។ ចំពោះយើង សេចក្ដីសុខលាយនិងការក្អឹតក្អើនរបស់យើងក្នុងមួយរយៈពេល ហាក់ដូចជាអំពើក្បត់មួយចំពោះប្រជាកសិករ ដែលកំពុងរងទុក្ខវេទនាដោយសារសង្គ្រាម។ យើងគួរតែហ៊ានធ្វើអ្វីមួយជាវិភាគទាន ក្នុងការបំបាត់សង្គ្រាមនេះ។

សេចក្ដីសំរេចចិត្តរបស់យើងក្នុងការចូលទៅក្នុងជួរ «បក្ស» អាចឲ្យមិត្តភក្តិរបស់យើងបកស្រាយច្រើនបែបច្រើនយ៉ាងណាស់មកលើរូបយើង។ ឬមួយគេចាត់ទុកយើងជាអ្នកផ្សងព្រេងនិយម ជាពួកឆ្កួតលីលា ជាក្រុមប្រលោមលោកនិយម (Les romantistes) ព្រោះថាខ្លួនឯងអាច «ទូលផែនដី» ឬទេ? ឬមួយគេអាចចាត់ទុកយើងថា ជាពួកសីហនុនិយម? ឬមួយគេចោទយើងថាជាកុម្មុយនិស្ត?

ចំពោះយើង យើងសុខចិត្តនៅស្ងៀមជាជាងស្រដី។

នៅថ្ងៃទី ៩ ឧសភា យន្តហោះ តេ-២៨ ២គ្រឿង មកទំលាក់គ្រាប់បែកនៅខាងជើងវត្តកាត់ក្ដុក។

ថ្ងៃទី ១០ ឧសភា... ការអផ្សុកនិងរវើរវាយញាំញីយើងកាន់តែខ្លាំងឡើងៗ ។ យើងគ្មានសៀវភៅមើលកំសាន្ត គ្មានកាសែត។ យើងដាច់ការទាក់ទងពីខាងក្រៅ ពីភ្នំពេញ។ មួយថ្ងៃៗ យើងស្ដាប់ដំណឹងតែតាមវិទ្យុភ្នំពេញ ប៉េកាំង វ៉ាស៊ីងតោន។

ដំណឹងថាក្រុងភ្នំពេញទទួលការវាយប្រហារដោយគ្រាប់កាំភ្លើងត្បាល់ និងគ្រាប់រ៉ុក្កែត 122 mm. ចំនួន ១៥៥ គ្រាប់នៅដើមខែឧសភា ធ្វើឲ្យយើងរន្ធត់ញាប់ញ័រជាខ្លាំង។

នៅល្ងាចថ្ងៃទី ១០ ឧសភា មិត្ត មាំង កូឈ្នួយមិត្ត ចាន់ បានយកសំបុត្រមួយមកបង្ហាញយើង។ ក្នុងលិខិតនោះ ស្នងការនយោបាយតំបន់ ៣៣ (មិត្ត សាំង-រិន, អតីតសាស្ត្រាចារ្យមធ្យមសិក្សា) បាន «ស្នើ» ឲ្យមិត្ត មាំង នាំយើងទៅជួបនឹងគេនៅវេទិកាកិត្តិយស នៅវេលាម៉ោង ៦ ល្ងាច។ នៅល្ងាចថ្ងៃ ១០ ឧសភានោះ គណៈរណសិរ្សតំបន់ ៣៣ បានចាត់ចែងរៀបចំមីទីងមួយយ៉ាងធំ នៅក្បែរវត្តកាត់ក្ដុក ត្រង់សាលារៀនបឋមសិក្សាចាស់។

យើងបានចូលរួមមីទីងនឹងគេដែរ តែមិត្ត មាំង យើងមិនដឹងជាមានចេតនាបែបណា ពុំបាននាំយើងទៅជួបអ្នកដឹកនាំខ្មែរក្រហមនៅវេទិកាកិត្តិយសទេ។

យើងមានការចាប់អារម្មណ៍ជាខ្លាំងទៅលើមីទីងនេះ។ មនុស្សប្រមាណជាង ១ ម៉ឺននាក់ រួមទាំង «ប្រជាជន» ទាំង «កងកម្លាំងប្រដាប់អាវុធប្រជាជនរំដោះជាតិកម្ពុជា» ទាំងព្រះសង្ឃ ទាំងក្របខណ្ឌខ្មែរក្រហម (កម្មាភិបាល) ប្រដាប់ដោយសម្លៀកបំពាក់ខ្មៅ បានចេញមកពីគ្រប់ទិសទី ហែជាក្បួនកាន់ទង់ក្រហម និងបដាក្រហមតំរង់មកកាន់ធ្លាសាលារៀន។ ក្រុមនារីឈរនៅជួរខាងមុខក្បែរវេទិកា។ នៅមុខវេទិកា មានសង់តូប មីក្រូ ដាច់ឆ្ងាយពីគ្នា។ ខាងក្នុងវេទិកាមានកៅអីប្រមាណ ២០០ តំរៀបជាជួរ។

ដំបូង អារម្មណ៍របស់យើងបាញ់ផ្តោតទៅលើពាក្យស្លោកនៅលើបដាក្រហម។ បណ្តាបដាជាច្រើន យើងឃើញមានតែបដាក្រហមមួយទេដែលចែងថា, «ជយោ! រណសិរ្សរួបរួមជាតិកម្ពុជា ដែលមានសម្តេច នរោត្តម-សីហនុ ព្រះប្រមុខរដ្ឋជាប្រធាន» ក្រៅពីនេះ គ្មានបដាក្រហមណាមួយនិយាយពីស្តេចសីហនុឡើយ។ ពាក្យស្លោកភាគច្រើន បញ្ចើចបញ្ចើរពីវីរភាពរបស់ប្រជាជន និងកងកំឡាំងរបស់គេ ដូចជា:

«ជយោ! កងកំឡាំងប្រដាប់អាវុធប្រជាជនរំដោះជាតិកម្ពុជាដ៏មានជ័យ»

«ប្តេជ្ញាគាំទ្រការតស៊ូដ៏អង់អាចក្លាហានរបស់ប្រជាជន»

«ជយោ! រដ្ឋអំណាចប្រជាជន!»

«ប្តេជ្ញាកំទេចចក្រពត្តិអាមេរិកាំង និងបរិវាររាវាឲ្យអស់ពីទឹកដីកម្ពុជា លាវ វៀតណាម»

«ជយោ! យុទ្ធសាមគ្គីនៃប្រជាជនខ្មែរ លាវ និងវៀតណាម» ....។ល។

ដោយឃើញបដាពីរ សំដែងពរស្វាគមន៍ចំពោះលោក ហ៊ូ-យន់ ទើបយើងដឹងថាលោក ហ៊ូ-យន់ ច្បាស់ជាមកជាអធិបតីក្នុងពិធីនេះ។

យើងខិតខំផ្ទៀងរកមើល ក្រែងមានយៀកកុងយៀកណាមខាងជើងមកចូលរួមក្នុងពិធីបុណ្យមីទីងនេះ តែយើងរកមើលពុំមានម្នាក់សោះ។

ភ្លើងអគ្គិសនីបានបំភ្លឺព្រោងព្រាត ហាក់ដូចជាពុំមែនជាជនបទ។ នៅក្បែរវេទិកា គេបានរៀបចំលេណដ្ឋានមានគំរបមួយយ៉ាងមាំសំរាប់មេដឹកនាំខ្មែរក្រហម។ នៅជុំវិញទីធ្លាសាលាមានគេជីកលេណ-ដ្ឋានតូចៗ យ៉ាងច្រើនសំរាប់ទស្សនិកជន។ ក្រុមឲ្យសញ្ញាថាមានយន្តហោះ បណ្តាក់គ្នានៅជុំវិញបរិ-វេណសាលា។ ពេលព្លសូរកញ្ចែ ភ្លើងអគ្គិសនីត្រូវពន្លត់ បារីមិនត្រូវជក់។

នៅម៉ោង ៨ យប់ យើងឮប្រធានគណៈកម្មការរៀបចំមីទីងស្រែកជយោឃោសជូនពរដល់លោក ហ៊ូ-យន់ មានសំដីថា៖ «ជយោ! មិត្ត ហ៊ូ-យន់ បុត្រដ៏ឆ្នើមរបស់ប្រទេសកម្ពុជា»។ ស្នូរទះដៃលាន់ឮប្រាវៗ ព្រមជាមួយនោះទស្សនិកជនក៏ក្រោកឈរស្រែឡើង អើតរកមើលលោក ហ៊ូ-យន់។ យើងភ្ញាក់ព្រើតកាលបើឃើញលោក ហ៊ូ-យន់ ទាំងសាច់ទាំងឈាមលើកដៃទទួលការអបអរសាទរនៅជួរខាងមុខវេទិកា។

បន្ទាប់ពីសុន្ទរកថារបស់ប្រធានចាត់ចែងបុណ្យមីទីងមក លោក ហ៊ូ-យន់ ក៏បានឡើងថ្លែងសុន្ទរកថាយ៉ាងវែងដោយឥតព្រាងទុក អស់រយៈពេលប្រហែល ៣ ម៉ោង។ លោក ហ៊ូ-យន់ បានសង្កត់ហើយសង្កត់ទៀតថាជំហររបស់គេ គឺ «មិនចរចា មិនសំរុះសំរួល មិនរាថយ» គេប្រយុទ្ធរហូតបានជ័យជំនះជាស្ថាពរ ទោះជាត្រូវឆ្លងការលំបាកវេទនាយ៉ាងណាក៏ដោយ។ គេប្រកាន់ជំហរ “ឯករាជ្យម្ចាស់ការខ្លួនទីពឹងខ្លួន” ជាធំ តែគេ «ក៏ត្រូវរួមសាមគ្គីជាមួយប្រជាជនលាវនិងវៀតណាម ក្នុងការដេញចក្រពត្តិអាមេរិកាំងចេញពីឥណ្ឌូចិន»។

បន្ទាប់ពីសុន្ទរកថាលោក ហ៊ូ-យន់ មក, ព្រះសង្ឃ, «កម្មាភិបាល» ខ្មែរក្រហម, មេបញ្ជាការកងទ័ពស្នងការនយោបាយព្រមទាំងតំណាងខ្មែរក្រហម, មេបញ្ជាការកងទ័ពស្នងការនយោបាយ ព្រមទាំងតំណាងអណិកជនចិន-យួន ឡើងថ្លែងយោបល់គាំទ្រ «បដិវត្តន៍» របស់គេជាបន្តបន្ទាប់គ្នា ដែលតាមភាសារបស់គេហៅថា «ឡើងចាប់អារម្មណ៍»។

រាត្រីសិល្បៈបដិវត្តន៍របស់គេ បានកំដរទស្សនិកជននិងកងទ័ពរហូតដល់ម៉ោង ៥ ភ្លឺ។

រហូតមកដល់ពេលនេះ យើងធ្លាប់អោមត្រចៀកនឹងពាក្យពេចន៍ខ្ពស់ៗ របស់គេ និងភាសាមួយបែបថ្មីរបស់គេ និងពាក្យឃោសនាមួលបង្កាច់ទាំងទទឹងទិស មកលើរដ្ឋាភិបាល មកលើរបបសាធារណរដ្ឋ មកលើសង្គមនៅភ្នំពេញ ដែលពួកគេចាត់ទុកថាជា «សង្គមចាស់»។

<u>ថ្ងៃ ១២ ទៅ ១៤ ឧសភា ១៩៧២ :</u>

យើងធ្វើដំណើរចេញពីភូមិវាលល្មៀង នៅវេលាម៉ោង ៩ ព្រឹក ក្រោយពីការជំរាប និងថ្លែងអំណរគុណបងប្អូនញាតិមិត្រជិតខាងដែលបានជួយឧបត្ថម្ភយើងយ៉ាងកក់ក្ដៅអស់ចិរវេលា ២២ ថ្ងៃ ក្នុងការស្នាក់អាស្រ័យរបស់យើងនៅទីនេះ។ មន្ទីរនីរសោរបស់មិត្ត ចាន់ បានចាត់ឲ្យសហការីរបស់គេម្នាក់ជូនដំណើរយើង។ លើកនេះ យើងធ្វើដំណើរដោយទោចក្រយានឆ្ពោះទៅទិសខាងជើង តាមផ្លូវលំ ផ្លូវរទេះគោ ឆ្លងកាត់ភូមិតូចនានា ដែលមានសភាពស្ងាត់ជ្រងំ។ យើងឃើញផ្ទះបាក់បែកឆេះដោយគ្រាប់បែក ដើមដូង ដើមត្នោតបាក់រលំដោយគ្រាប់រ៉ុក្កែត គុម្ពឫស្សី ដើមស្វាយស្វិតស្រពោនរញ្ជមដោយគ្រាប់ណេប៉ាល់។ គឺជាទិដ្ឋភាពសង្គ្រាមគួរឲ្យខ្លាចផ្សា។

យើងបានមកដល់ភូមិប្រាំងចោតវេលាម៉ោង ១ កន្លះរសៀល បានចូលទៅសំរាកក្នុងជំរកកងឈ្លប និងក្រុមអ្នកនាំសារដែលសង់ប្រឫនឹងមាត់អូរ ក្រោមព្រៃឈើស៊ុបទ្រុប នៅខាងត្បូងភូមិចំងាយប្រមាណ ៣០០ ម៉ែត្រ។ យើងស្រស់ស្រូបបាយកញ្ចប់ដែលយើងយកមកជាប់នឹងខ្លួន។ នៅទីនេះ យើងបានជួបនឹងយុទ្ធជនរណសិរ្ស ៣ នាក់ទៀតដែលធ្វើដំណើរពីស្អាង-កោះធំ ឆ្ពោះទៅអមលាំង។ មានយុវជនពីរនាក់ដែលទើបនឹងចុះមកពី «ខាងលើ» (អង្គការលើ) បានប្រាប់យើងថា គេមានបេសកកម្មមកដឹកឥវ៉ាន់និងមកទទួលអស់លោក «ធំៗ»។ នៅម្ខាងផ្លូវជាតិលេខ ៤ ឯណោះ មានឡានកងជប់មួយមកចាំទទួលលោក ហ៊ូ-យន់ និងសហការីរបស់លោកដែលបានចូលរួមក្នុងមីទីងនៅកាត់ក្ដុក នាយប់ថ្ងៃ ១០ ឧសភា។

មិត្ត សន អ្នកនាំផ្លូវរបស់យើងព្រមទាំងមិត្តរួមដំណើរដទៃទៀតប្រហែល ១០ នាក់ បានមកដល់វត្តពុទ្រា ក្បែរផ្លូវជាតិលេខ ៤ នៅម៉ោង ៤ កន្លះរសៀល កងឈ្លប ៤-៥ នាក់បានទៅពិនិត្យផ្លូវនិងយាមនៅទីនោះ សំរាប់ធ្វើសញ្ញាឲ្យយើងឆ្លង។ នៅសងខាងយើងប្រហែល ៥ គ.ម. មានបន្ទាយកងទ័ពសាធារណរដ្ឋយើង។

នៅម៉ោង ៥ កន្លះ យើងបានឆ្លងកាត់ផ្លូវជាតិលេខ ៤។ កងឈ្លបដើរមុខធ្វើសញ្ញាឲ្យយើងឈប់ព្រោះផ្លូវរទេះមានបង្កប់មីន។ កងឈ្លបក៏គូសរង្វង់ហ៊ុំព័ទ្ធមីន និងធ្វើសញ្ញាឲ្យយើងដើរលើស្មៅវាងផ្លូវខ្សាច់ៗ ឆ្លងបានចំងាយប្រមាណ ៣០០ ម៉ែត្រ យើងក៏នាំគ្នាឡើងជិះកង់ បន្តដំណើរទៅមុខទៀត កាត់តាមវាលស្រែ ឬឆ្លងអូរ។

នៅម៉ោង ៦ និង ១៥ នាទីល្ងាច យើងបានមកឈប់សំរាកនៅក្នុងវត្តគោករមៀត។ ភូមិគោករមៀត ជាភូមិចាស់សំបូរទៅដោយដើមដូង ដើមស្វាយ ចេក ស្វា។ ផ្ទះក្បឿងធំៗ ជាច្រើនត្រូវបិទទ្វារចោល។ ក្រៅពីព្រះសង្ឃ ៦-៧ អង្គនៅក្នុងវត្ត ភូមិមានសភាពស្ងាត់ជ្រងំ។ យើងអង្គុយសំរាកនៅប្របមាត់ស្រះមួយ ដែលភ្ជាប់នឹងត្រពាំងបុរាណមួយយ៉ាងធំ។ រស្មីព្រះអាទិត្យស្រទន់ពណ៌មាសជះមកលើកំពូលភ្នំពីរនៅខាងកើតយើង ធ្វើឲ្យយើងនឹកស្តាយដល់សេចក្តីសុខសាន្តដែលបានវិនាសផុតទៅ... ដោយសារសង្គ្រាម... ដោយសារមហិច្ឆតារបស់យួនកុម្មុយនិស្ត! វត្តអារាម ដើមដូងខ្ពស់លលៃមានចំណាស់ប្រហែល ៥០ ឆ្នាំ ដើមស្វាយមានគល់ប៉ុនកង់រទេះ ត្រពាំង ។ល។ ទាំងអស់នេះគឺជាព្រលឹងនៃជីវិតធ្លាប់សុខសាន្តរបស់អ្នកភូមិ! ជានិមិត្តរូបនៃព្រលឹងខ្មែរតែម្តង!

យប់ថ្ងៃ ១២ មក ១៣ ឧសភា យើងបានទទួលដំណេកនៅក្នុងជំរំ «នីរសា» នៅខាងលិចភូមិគោករមៀត ប្របនឹងមាត់ស៊ឹងព្រៃរមៀត។ ព្រឹកថ្ងៃ ១៣ ឧសភា យើងបន្តដំណើរទៅមុខទៀត កាត់តាមព្រៃស្រោង វាលព្រេច។ យើងកំរជួបប្រទះភូមិជនបទអ្នកស្រុកណាមួយនៅតាមផ្លូវលំ។ នៅម៉ោង ២ កន្លះរសៀល យើងបានមកដល់ភូមិតោងម៉ោង (ឬតោងហោង?) ដែលមានចំងាយ ៧០ គ.ម. ពីថ្នល់ជាតិលេខ ៤ ។ នៅតាមផ្លូវ យើងបានជួបប្រទះយៀកកុង-យៀកណាមខាងជើងដឹកជញ្ជូនហឹបគ្រាប់តាមដាំរី ឬឡានកងដប់ ហ្សេ អឹម សេ (GMC)។ ចាប់ពីភូមិតោងម៉ោងទៅ យើងជិះឡានកងដប់យៀកណាមខាងជើងឆ្ពោះទៅស្រុកអមលាំង។ នៅខាងឆ្វេងយើង ភ្នំឱរ៉ាល់បានលេចរូបរាងត្រដែត។ គឺជាជំរកយុទ្ធសាស្រ្តរបស់ខ្មែរក្រហមតាំងពីយូរយារណាស់មកហើយ។

នៅព្រឹកថ្ងៃ ១៤ ឧសភា យើងចេញដំណើរដោយកងពីស្រុកអមលាំងឆ្ពោះទៅទិសខាងត្បូងតាមថ្នល់ខេត្ត (Route Provinciale)។ នៅតាមផ្លូវ យើងបានជួបមនុស្សម្នាជាច្រើន ជាយុទ្ធជនខ្មែរក្រហម ឬពួក «អង្គការ» ចុះឡើងទៅមកអមលាំងមិនដាច់។ ទាំងអស់គ្នាសុទ្ធសឹងតែស្លៀកពាក់ខ្មៅ មានបង់-ក្រមាដូចគ្នា។

នៅវេលាម៉ោង ២ រសៀល យើងបានមកដល់វត្តពោធិ៍។ នៅម៉ោង ៤ យើងចូលមកដល់ភូមិតាំងខ្មៅ ក្នុងសង្កាត់ពាមប្រាំបីមុម ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង។ មិត្ត សន បាននាំយើងចូលទៅសំរាកក្នុងមន្ទីរនីរសានៃតំបន់ ៣០៥ ហើយបានប្រាប់យើងថា យើងមកដល់គោលដៅហើយ។ យើងបានប្រាប់នីរសានៅទីនោះថា យើងមានលិខិតមួយត្រូវយកទៅជូនមិត្ត «ហង់» មន្ទីរ ៣០៥ ដោយផ្ទាល់។ មិត្តនីរសាគេមិនឲ្យយើងទៅជួបមិត្ត ហង់ នោះផ្ទាល់ទេ គេទទួលយកលិខិតពីយើងទៅជូនមិត្តហង់។ យើងនៅរង់ចាំអស់រយៈពេលជិតមួយម៉ោង រួចទើបឃើញមិត្តនីរសានោះវិលត្រឡប់មកវិញហុចកូនសំបុត្រមួយទៅឲ្យមិត្ត សន។ អ្នកនាំផ្លូវយើងសើចញញឹមញញែម បង្ហាញកូនសំបុត្រនោះមកឲ្យយើងអាន មានអក្សរតែមួយបន្ទាត់មានសេចក្តីថា, “សូមបង នាគ លៃលករៀបចំកន្ទែងឲ្យបានសមរម្យដល់មិត្តបញ្ញាជន... ពីក្រុងផង ព្រោះខ្ញុំគ្មានមធ្យោបាយ”។ មិត្ត សន បន្ថែមថា “បងមានសំណាងហើយ ដោយបានមន្ទីរសេដ្ឋកិច្ចភាគរៀបចំទទួលផ្ទាល់”។ មិត្តសន ក៏បាននាំយើងទៅកាន់មន្ទីរមិត្ត «នាគ» (ឈ្មោះបដិវត្តន៍) ដែលនៅប្របមាត់ស៊ឹងខាងលិចវត្តតាំងខ្មៅ។

ពេលចូលទៅដល់ យើងបានជួបប្រទះនឹងយុវនារីមួយក្រុមកំពុងប្រជុំ «រៀនសូត្រនយោបាយ» នៅក្រោមដើមចំបក់មួយដ៏ធំ។ មានតុមួយវែងសំរាប់ជាកន្លែង «ហូប» បាយផង ជាកន្លែងប្រជុំផង។ មិត្តនារីទាំងអស់នេះជាក្រុមកាត់ដេរ។ បន្តិចក្រោយមក យើងឃើញកូនចៅចិនម្នាក់ រូបស្អាតបាត

*ដើរតាំងមករកចាប់ដៃយើងដោយទឹកមុខញញឹមរាក់ទាក់។ មិត្ត នាគ បានសាកសួរសុខទុក្ខ និងសុំទោសយើងដោយពុំបានយកឡានទៅទទួល។ គេបានបញ្ជាក់ទៀតថា បានទទួលទូរលេខមួយពីមិត្ត ចាន់ ស្តីពីវត្តមានរបស់យើង។ មិត្ត នាគ នេះគឺគ្មាននរណាក្រៅពីលោក សៀង-ប៉ៅសែ អតីតវិស្វករ និងអតីតនាយកក្រសួងសុរិយោដីនោះទេ។*

*នៅទីនេះជាដំបូង យើងបានទទួលកិត្តិយស និងការថ្នាក់ថ្នមពីសំណាក់មិត្ត នាគ គឺយើងមានវាសនាបានស្រស់ស្រូបកាហ្វេទឹកដោះគោ យូរៗ ម្តង។ មិត្ត នាគ ឲ្យបញ្ជាទៅមិត្តនារីកាត់ដេរទាំងនោះ ឲ្យរៀបចំម្ហូបអាហាររបស់យើងដោយឡែក។ ក្រោយមក យើងទទូចចូលរួម «ហូប» បាយទឹកជាមួយមិត្តឯទៀតៗ ដោយមានម្ហូបតែមួយមុខដូចគ្នា។*

*<u>ថ្ងៃ ១៤ ដល់ ២៦ ឧសភា</u> :*

*មិត្ត នាគ បានប្រគល់អង្រឹងនីឡុងថ្មីមួយមកឲ្យយើង ហើយទូន្មានយើងឲ្យរក្សាការសំងាត់ គឺលាក់ឈ្មោះដើម មុខងារ ស្រុកកំណើតរបស់យើងកុំឲ្យនរណាដឹង លើកលែងតែអង្គការថ្នាក់លើ។*

*នៅថ្ងៃ ១៥ ឧសភា វេលាម៉ោង ៧ យប់ លោក ហ៊ូ-យន់ ជារដ្ឋមន្ត្រីក្រសួងមហាផ្ទៃទទួលបន្ទុករៀបចំជនបទនិងសហករណ៍ ដែលយើងបានជួបម្តងហើយនៅជិតស្រុកបរសែត បានចូលទៅសាកសួរសុខទុក្ខយើង ជាមួយវរជនម្នាក់ទៀតឈ្មោះ សុខ-ធួក មានងារជាអនុរដ្ឋមន្ត្រីក្រសួងសន្តិសុខជាតិក្នុងរដ្ឋាភិបាលរណសិរ្សរបស់សីហនុ និងជាប្រធានភូមិភាគពិសេស (មន្ទីរ ៣០៥)។*

*នៅថ្ងៃទី ១៥ ឧសភាដដែលវេលាម៉ោង ៤ រសៀល យើងបានជួបសន្ទនាលេងជាមួយសមាជិកនៃមន្ទីរឃោសនាការភូមិភាគពិសេសចំនួន ៣ នាក់ទៀត គឺមិត្ត ឈុន-សុខង៉ួន ជាវិស្វករមានឈ្មោះក្រៅហៅ «សោម» មិត្ត សៀក-តឹកឆាយ ហៅ ថន អតីតសាស្ត្រាចារ្យមធ្យមសិក្សាបឋមភូមិ និងមិត្ត ឌៀន-ភីកាន ហៅ រិន អតីតគ្រូបង្រៀន។ ក្នុងថ្ងៃដដែល មិត្ត ម៉ែន-នីថូ ហៅ ដន អតីតវិស្វករខាងអគ្គិសនី បានចូលទៅជួបរាក់ទាក់ជាមួយយើងផងដែរ។ នៅមន្ទីរសេដ្ឋកិច្ចភាគនេះ យើងតែងបានជួបកម្មាភិបាលខ្មែរក្រហមជាច្រើនរូបទៀត ដែលជាអតីតរដ្ឋការ អតីតនិស្សិតនៅក្រុងភ្នំពេញ។ គេពុំទាន់ប្រគល់ភារកិច្ចអ្វីឲ្យយើងធ្វើទេ។ មួយថ្ងៃៗ យើងរវល់តែទទួលភ្ញៀវ និងអានឯកសារផ្សេងៗ ដែលមិត្ត នាគ បានប្រគល់មកឲ្យយើង មានទស្សនាវដ្តីរណសិរ្ស កាសែត «ពលករបដិវត្តន៍» កាសែត «ប្រជាជនបដិវត្តន៍» ជាដើម។ យើងកាន់តែអផ្សុកខ្លាំងឡើងៗ ព្រោះយើងគ្មានសេរីភាពចេញដើរតាមភូមិជិតៗខាងបានទេ។*

*នៅក្នុងភូមិនេះ គេបាននិយាយប្រាប់យើងថា លោក ចេង-សាយុំប៊ិន នៅឆ្ងាយពីយើងប្រហែល ៥០០ ឬ ៦០០ ម៉ែត្រប៉ុណ្ណោះ គឺនៅភូមិតាំងខ្មៅ ប៉ែកខាងកើត។ គាត់រស់នៅជាមួយប្រពន្ធកូនរបស់គាត់ក្នុងភូមិអ្នកស្រុក។ «អង្គការ» ជួយចិញ្ចឹមគ្រួសារលោក ចេង-សាយុំប៊ិន តែពុំទាន់ហ៊ានប្រគល់ភារកិច្ចអ្វីមួយឲ្យគាត់ទេ។*

*នៅថ្ងៃ ២១ ឧសភា វេលាម៉ោង ៦ ល្ងាច មិត្ត នាគ បាននាំយើងទៅចូលរួមបាយទឹកជាមួយលោក ហ៊ូ-យន់ នៅមាត់ស្ទឹង។ គឺនៅពេលនេះហើយ ដែលយើងបានជួបមិត្ត ហង់ (យើងស្រាវជ្រាវរកឈ្មោះដើមនិងមុខងារបាស់ពុំលេចសោះ)។ អនុប្រធានភូមិភាគពិសេស លោក រស់-ជាទ្នោ ហៅ*

ជាតិ លោក ង៉ួន-អេង ហៅ នី (អតីតវិស្វករ) លោក កុយ-អ៊ុំ ហៅ ទីប (ធ្វើការនៅអយស្ម័យយានកម្ពុជា) និងស្ហួលខ្មែរក្រហម ៣-៤ នាក់ទៀតដែលយើងពុំស្គាល់ឈ្មោះៗ ប្រពន្ធលោក សៀង-ប៉ោសែ ប្រពន្ធមិត្ត ហង់ និងមិត្តនារីកាត់ដេរជាអ្នកចាត់ចែងរៀបចំម្ហូបចំណីពិសេសនេះៗ

លោក ហ៊ូ-យន់ មានអង្គរក្សម្នាក់ជាខ្មែរលើនៅរតនគីរី ដើរតាមការពារជានិច្ចៗ

នៅថ្ងៃទី ២២ ឧសភា យើងបានជួបពិភាក្សាជាមួយលោក ធុច-រិន ហៅ គ្រិន អតីតសាស្ត្រាចារ្យមធ្យមសិក្សា ជាប្រធានមន្ទីរវប្បធម៌នៅភូមិភាគនិរតីទិស ដែលមានទីតាំងនៅក្បែរទីរួមស្រុកអមលាំងៗ ដោយសារម្ហូបចំណីមិនគ្រប់គ្រាន់ និងដោយសារយើងរស់នៅក្រោមដើមឈើស៊ីបទ្រូបទាំងយប់ថ្ងៃ សុខភាពរបស់ខ្ញុំកាន់តែទ្រុឌទ្រោមបន្តិចម្តងៗៗ ភាពទំនេរគ្មានការធ្វើរឹតតែធ្វើឲ្យយើងអផ្សុកខ្លាំងឡើងៗៗ ម្យ៉ាងទៀត និន្នាការនយោបាយតាមគន្លងចិនក្រហម និងផ្ទត់គំនិតឆ្វេងនិយមហួសហេតុរបស់ស្ហួលខ្មែរក្រហមភាគច្រើនរឹតតែធ្វើឲ្យយើងស្រងាកចិត្តយ៉ាងខ្លាំងៗ ការជួបពិភាក្សាជាហូរហែជាមួយ «ស្ហួលខ្មែរក្រហម» ក៏រឹតតែធ្វើឲ្យយើងអស់សង្ឃឹមថាខ្មែរខាងណោះ និងខ្មែរខាងណេះ ប្រហែលជាពុំអាចធ្វើការចរចាសំរុះសំរួលគ្នាកើតទេៗ បន្តិចម្តងៗ យើងកាន់តែយល់នូវឥរិយាបថពិតប្រាកដរបស់ខ្មែរក្រហមៗ

សំនួរទាំងអប្បាលមាណ ដែលយើងរកចំឡើយពុំឃើញមានសមហេតុសមផល ឥឡូវឡើងចូលមកប្រឡូកក្នុងចំឡើយទាំងនោះហើយៗ ចំពោះយើង យើងប្រកាន់ជំហរតែមួយរបស់យើង គឺៈ «សង្គមខ្មែរនិងលទ្ធិកុម្មុយនិស្ត» មិនស៊ីសង្វាក់គ្នាទេៗ យើងធ្លាប់ល្បងធ្វើការត្រិះរិះខ្លះៗ មកហើយ ទៅលើទំនាស់ធំៗ រវាងសង្គមជាតិខ្មែរនិងលទ្ធិក្រហមនេះៗ

ថ្ងៃ ២៦ ឧសភា ដល់ថ្ងៃ ៣ មិថុនា ១៩៧២ :

នៅល្ងាចថ្ងៃ ២៦ ឧសភា មិត្ត នាគ បានប្រាប់ឲ្យយើងរៀបចំឥវ៉ាន់ ដើម្បីទៅចូលរួមក្នុងមហាសន្និបាតបញ្ញវន្តនីងគេៗ យើងបានទទួលមុង ១, ខោអាវខ្មៅ ១ សំរាប់ និងស្បោង (Sac à dos ) ខ្មៅ ១ ពីមិត្ត នាគៗ នៅវេលាម៉ោង ៥ ល្ងាច លោក រស់-ជាទ្វោ មកនាំយើងទៅចូលរួមក្នុងមហាសន្និបាតដែលនឹងធ្វើឡើងនៅក្នុងសាលារៀន «នយោបាយ» នៅខាងជើងតាំងខ្មៅៗ នៅទីនោះ យើងបានជួបសន្ទនាជាមួយវរជនសំខាន់ៗ ជាច្រើនដែលបាត់ខ្លួនពីក្រុងភ្នំពេញៗ ទ្រង់ នរោត្តម ភូរិស្សរា ដែលកំពុងឈរនិយាយជាមួយលោក ហ៊ូ-យន់ បានស្ទុះមកចាប់ដៃយើងមុនគេៗ បន្ទាប់មក យើងក៏សំដែងការគួរសមចំពោះ «សមមិត្ត» ឯទៀតៗ មានជាអាទិ៍លោកវេជ្ជបណ្ឌិត ជួន-ជឿន និងភរិយា, លោកវេជ្ជបណ្ឌិត ឌី-ផុន ហៅ ធុក, លោក យៀង-កាអុន, លោក កោក-ឆាយ ហៅ ណាង, លោក ធុច-រិន ហៅ គ្រិន, លោក ម៉ែន-នីថូ ហៅ ដន, លោក ង៉ួន-អេង ហៅ ទី, លោក ចន្ទ-បុប្ផា ហៅ ខុម (អតីតចៅក្រម), លោក យូ-ថាន ហៅ ផល (អតីតសាស្ត្រាចារ្យ), លោក សៀក-តឹកឆាយ ហៅ ថន, លោក ស្រី-ដួង ហៅ ខែ (វិស្វករ), លោក ឌៀន-គីកាន ហៅ វិន (គ្រូបង្រៀន) និងពួកបញ្ញាជនដទៃទៀតដែលមានទាំងអស់ប្រហែល ៥០-៦០ នាក់ៗ

នៅជុំវិញសាលារៀននយោបាយ គេមានសង់រោង ៥-៦ សំរាប់ធ្វើជាកន្លែងដំណេកនិងរោងបាយផងមួយៗ មិត្តនារីមួយក្រុមទទួលភារៈរៀបចំម្ហូបចំណី និងថ្នាំសង្កូវសំរាប់ពួកបញ្ញាជនទាំងអស់ៗ គេបានរៀបចំកម្មវិធីដូចតទៅ គឺ៖ រាល់ពេលព្រឹក

- ម៉ោង ៦ និង ៣០ នាទី : ស្រស់ស្រូបបបរ ឬបាយ
- ម៉ោង ៧ ដល់ម៉ោង ១១ : ប្រជុំពិភាក្សាក្នុងសាលារៀន
- ម៉ោង ១១ និង ៣០ នាទី : បាយថ្ងៃត្រង់
- ម៉ោង ១៤ ដល់ម៉ោង ១៧ : ប្រជុំពិភាក្សាក្នុងសាលារៀន
- ម៉ោង ១៧ និង ៣០ នាទី : បាយល្ងាច
- ម៉ោង ២០ ដល់ ២១ ឬ ២២ : ប្រជុំធ្វើការទិតៀន និងស្វ័យទិតៀន តាមពួកនិមួយៗ ដែលគេហៅថា ប្រជុំជីវភាពៗ

កិច្ចការសន្និបាតនេះ រៀបចំឡើងដោយគណៈកម្មការរណសិរ្សក្រុងភ្នំពេញ ដែលមានសមាសភាពដូចតទៅ :

១- នរោត្តម-កូវិស្សរា ហៅ កែន : ប្រធាន
២- វេជ្ជបណ្ឌិត ជួន-ជឿន ហៅ ប៉ែន : អនុប្រធាន
៣- លោក រស់-ជាទ្វោ ហៅ ជាតិ : សមាជិក ទទួលបន្ទុកខាងសារពត៌មាន
៤- លោក ង៉ួន-អេង : សមាជិក តំណាងសហជីពកម្មករ និង ពលករ
៥- លោក កោត-ឆាយ : សមាជិក តំណាងនិស្សិត និង បញ្ញាជន
៦- អ្នកស្រី ខៀវ-ប៉ុណ្ណារី : សមាជិក តំណាងនារីប្រជាធិបតេយ្យ

ភូមិភាគពិសេសរបស់ខ្មែរក្រហមនេះ មានភារៈត្រួតត្រាកាន់កាប់ទឹកដីជុំវិញភ្នំពេញ និងក្រុងភ្នំពេញ ដូចយោធភូមិភាគពិសេសរបស់យើងដែរ (RMS)ៗ

នៅថ្ងៃ ២៧ ឧសភា វេលាម៉ោង ៧ ព្រឹក លោក រស់-ជាទ្វោ បានឡើងប្រកាសកម្មវិធីជូនអង្គប្រជុំស្តាប់ និងចាត់ចែងរៀបចំសមាជិកទាំងអស់ ជាពួកៗ រួចហើយក៏ផ្ទេរសំដីជូនទៅទ្រង់ កូវិស្សរាៗ ទ្រង់ កូវិស្សរា ក្រោយពីបានថ្លែងសុន្ទរកថាស្វាគមន៍ និងជូនពរដល់ជោគជ័យនៃមហាសន្និបាតមក ក៏ជូនសំដីទៅលោក ហ៊ូ-យន់ តទៅទៀតៗ

នៅក្នុងមហាសន្និបាតបញ្ញវន្តនេះ គេពុំបានប្រាប់ឲ្យដឹងជាមុនទូវរបៀបវារៈទេៗ ដំបូងលោក ហ៊ូ-យន់ បានធ្វើវិភាគទៅលើសភាពការណ៍ នៅក្នុងសាកលលោក ដែលអាចជះឥទ្ធិពលមកលើ «បដិវត្តន៍» របស់គេៗ គេធ្វើវិភាគនេះ តាមរបៀបវិភាគ ម៉ាក្សិស្តឡេនីនិស្ត (Méthode marxiste léniniste d'analyse des évènements sociaux) ដែលពួកគេបានឲ្យតម្លៃថា មានលក្ខណៈវិទ្យាសាស្ត្រៗ

បន្ទាប់មក លោក ហ៊ូ-យន់ មកធ្វើវិភាគទៅលើសភាពការណ៍ក្នុងស្រុក ទៅលើសម្ពន្ធភាពនិងយុទ្ធសាមគ្គីរវាងប្រជាជន លាវ-ខ្មែរ-វៀតណាម ជាពិសេសនៅលើសម្ពន្ធភាពរវាងយៀកកុង-យៀកណាមខាងជើង និងខ្មែរក្រហមៗ លោក ហ៊ូ-យន់ បានបំភ្លឺអង្គប្រជុំពីជំហររបស់បដិវត្តន៍គេ (ខ្មែរក្រហម) នៅក្នុងស្រុកនិងលើឆាកអន្តរជាតិៗ

នៅក្នុងស្រុក លោក ហ៊ូ-យន់ បានសារភាពថា នៅឆ្នាំ ១៩៧០-៧១ ពួកយៀកកុង-យៀកណាមខាងជើង (ខ្មែរក្រហមនិយមហៅមិត្តទី ៧ តាមជំហរទី ៣ បន្ទាប់ពីចិនប្រជាមានិត និងអាល់បានី) បានលួចប្លន់ទ្រព្យសម្បត្តិអ្នកស្រុក ជិះជាន់លួចកាប់សម្លាប់ខ្មែរក្រហម ហើយគ្របសង្កត់ទៅលើកម្មាភិបាលខ្មែរក្រហមមែន ព្រោះពេលនោះ កម្លាំងខ្មែរក្រហមនៅខ្សោយ ខ្វះអាវុធ គ្មានកងទ័ពមាំមួនៗ ពួកយៀកកុង-យៀកណាមខាងជើង បានរឹបអូសសង្កត់សង្កិនយកមាសប្រាក់ប្រជាពលរដ្ឋជាច្រើន យកទៅចិញ្ចឹមពួកវា ដូចជានៅតំបន់ស្អាង-កោះធំ ជាដើមៗ ទាល់តែមកដល់ចុងឆ្នាំ ១៩៧១ ទើបពួកខ្មែរក្រហម ឬខ្មែររំដោះ បានរើបំរះខ្លួនមកវិញបាន មិននៅក្រោមឥទ្ធិពលយៀកកុង-យៀកណាមខាងជើងទេៗ

ឥឡូវនេះ យើងប្រកាន់ជំហរឯករាជ្យម្ចាស់ការ ខ្លួនទីពឹងខ្លួនជាធំៗ យៀកកុង-យៀកណាមខាងជើងត្រូវគោរពប្រជាជនខ្មែរជាដាច់ខាត គោរពអង្គការខ្មែរ ហើយជួយច្បាំងដេញចក្រពត្តិអាមេរិកាំងនិងបរិវារវាៗ នេះជាសំដីរបស់លោក ហ៊ូ-យន់ៗ

ចំពោះសំនួររបស់ខ្ញុំមួយថា តើអង្គការមានការព្រួយបារម្ភខ្វះទេ ហើយរៀបចំវិធានការយ៉ាងណាដែរ ចំពោះទ័ពបរទេសយៀកកុង-យៀកណាមខាងជើងនៅក្នុងស្រុកខ្មែរ លោក ហ៊ូ-យន់ បានឆ្លើយថា អង្គការមានការព្រួយបារម្ភខ្វះដែរក្នុងរឿងនេះ តែអង្គការបានប្រុងប្រយ័ត្នជើងព្រួលស្រេចបាច់អស់ហើយៗ លោក ហ៊ូ-យន់ បានលើកសរសើរជំហររបស់អង្គការបដិវត្តន៍របស់គេនៅលើឆាកអន្តរជាតិ ហើយមានការពោលថា បក្សកុម្មុយនិស្តចិន និងកូរ៉េ គេសុំរៀនសូត្រពីយើង (ខ្មែរក្រហម) ទៀតផងៗ

ចំឡើយនិងសេចក្តីសន្និដ្ឋានរបស់លោក ហ៊ូ-យន់ នៅតែធ្វើឲ្យយើងមិនអស់សង្ស័យនិងគ្មានជំនឿដដែលៗ

នៅថ្ងៃបន្តបន្ទាប់មកទៀត អង្គប្រជុំបានបើកឲ្យមានការពិភាក្សាប្តូរយោបល់គ្នាទៅវិញទៅមក និងលើកសំនួរផ្សេងៗ មកចោទៗ លោក កោគ-ធាយ បានធ្វើសេចក្តីរាយការណ៍មួយស្តីពីជោគជ័យនៃទ័ពគេៗ នៅល្ងាចថ្ងៃទី ២ មិថុនា ១៩៧២ លោក រស់-ជាឡោ បានរៀបចំនិងថ្លែងសេចក្តីប្រកាសរួមមួយ ក្រោមចំណងជើងថា «សេចក្តីសំរេចចិត្តនៃមហាសន្និបាតបញ្ញាជនក្រុងភ្នំពេញ»ៗ នៅថ្ងៃដដែលវេលាម៉ោង ៦ ល្ងាច គេបានរៀបចំពិធីជប់លៀងបិទមហាសន្និបាតៗ

ខ្ញុំភ្លេចជំរាបថានៅថ្ងៃទី ២៩ ឧសភា លោក ជ័យ-ជុំ (វរមន្ត្រី) ដែលទើបនឹងចេញពីភ្នំពេញនៅថ្ងៃ ២៨ ឧសភា បានចូលរួមក្នុងមហាសន្និបាតនេះដែរៗ

នៅរាត្រីទី ២ មិថុនា គេបានរៀបចំរាត្រីសិល្បៈមួយ សំដែងដោយក្រុមសិល្បៈភូមិភាគពិសេស មានរបាំ អាយ៉ៃ ចំរៀង រឿងល្ខោនតូចៗ ។ នៅក្នុងរបាំ អាយ៉ៃ ឬរឿងកំប្លែង យើងពិនិត្យឃើញនូវលក្ខណៈប្រាំដែល នូវខ្លឹមសារដដែលៗ គ្មានផ្លាស់ប្តូរដូចជា ចំរៀង «ពួកកងឈ្លបយើង» របាំ «បង្កើតផល» កុមារឈានមុខ ។ល។ អាយ៉ៃត្រូវច្រៀងតាមពាក្យពេចន៍ដែលគេតែង និងចងក្រងឲ្យគ្មានការបំភ្លៃក្រៅទេៗ ជាខ្លឹមសារ គឺការបញ្ចើចបញ្ចើវណ្ណៈដែលត្រូវគេជិះជាន់ ( Les exploités ) មាន «កំហឹងធាបឆេះ» ជានិច្ចៗ លក្ខណៈទន់ភ្លន់ សន្តិភាព មនុស្សធម៌ ដែលមាននៅក្នុងខ្លឹមសារសិល្បៈបុរាណខ្មែរ បានប្រែក្លាយទៅជាឃោរឃៅ ញាក់កន្ត្រាក់ៗ ស្នូលខ្មែរក្រហមប្រហែលមានចេតនាបញ្ចូល

ផ្ទត់ «ម៉ាក្សិស្ត» ទៅក្នុងលំនាំបុរាណខ្មែរទេដឹង! យើងចាប់អារម្មណ៍ហាក់ដូចកំពុងទស្សនារបាំចិនកុម្មុយនិស្ត ឬរបាំយួនយៀកណាមខាងជើង! គួរឲ្យសង្វេគដល់ព្រលឹងខ្មែរ!!

# ជីវភាពនៅតាមមន្ទីរ (ការិយាល័យ) ខ្មែរក្រហម

*( ថ្ងៃ ៣ មិថុនា ១៩៧២ ដល់ថ្ងៃទី ១៥ មករា ១៩៧៣ )*

*នៅថ្ងៃទី ៣ មិថុនា ១៩៧២ យើងត្រូវ «អង្គការ» ចាត់ឲ្យទៅធ្វើការនៅមន្ទីរឃោសនាការនិងវប្បធម៌នៅភូមិភាគពិសេស។ មិត្ត ឈុន-សុកដួន អតីតវិស្វករ ជាប្រធានមន្ទីរឃោសនាការភូមិភាគពិសេសជំនួសលោក ជី-គីមអាន ដែលបានចងកសម្លាប់ខ្លួននៅដើមខែមេសា បាននាំយើងទៅកាន់ភូមិស្រែអណ្ដូង។ មន្ទីររបស់យើងសង់នៅលើទួលមួយខ្ពស់ ជាភូមិចាស់ដែលគេបានបោះបង់ចោល នៅខាងលិចវត្តស្រែអណ្ដូងចម្ងាយប្រមាណ ៥០០ ម៉ែត្រ ជាប់នឹងបរិវេណគោកខ្មោចស្រែអណ្ដូង។ ពេលយើងចូលទៅដល់ សមាជិកដទៃទៀតមានការចាប់អារម្មណ៍យកចិត្ត ទុកដាក់នឹងយើងជាខ្លាំង។ ក្រុមរបស់យើងមានសមាជិកទាំងអស់ ១៣ នាក់ ភាគច្រើនជាវិស្វករ និងជាបុគ្គលិកសិក្សាដែលនៅក្រោមឱវាទលោក រស់-ជាត្ថោ ផ្ទាល់។ លោក រស់-ជាត្ថោ ជាវរជនទី ៣ នៅភូមិភាគពិសេស បន្ទាប់ពីមិត្ត សុក-ធួក និង មិត្ត ហង់ មក។ ប្រធានមន្ទីរបានណែនាំពន្យល់យើងពីវិន័យរបស់អង្គការ ពីរបបរស់នៅក្នុងសមោហភាព ពីភារកិច្ចប្រចាំថ្ងៃដែលយើងត្រូវបំពេញ សមាជិកទាំង ១៣ នាក់ ត្រូវចែកជា ៣ ពួក។ ប្រធានមន្ទីរចាត់តាំងសហការីណាដែលមានទឹកចិត្តស្មោះត្រង់នឹងអង្គការ មានជំហរនយោបាយរឹងប៉ឹងជាងគេ ឲ្យធ្វើជាប្រធានពួក។ ពួកនីមួយៗ ត្រូវរួមប្រជុំមួយសប្ដាហ៍ម្ដង ដើម្បីតាមដានពិនិត្យជំហរគ្នាទៅវិញទៅមក គេហៅថា «ប្រជុំជីវភាព» ឬប្រជុំធ្វើការទិតៀននិងស្វ័យទិតៀន។ គេនាំគ្នាសន្មតយកល្ងាចថ្ងៃព្រហស្បតិ៍សំរាប់ «ប្រជុំពួក» និងល្ងាចថ្ងៃអាទិត្យសំរាប់ «ប្រជុំក្រុម» គឺប្រជុំ សមាជិកគ្រប់ពួកទាំងអស់។*

*<u>ទីកន្លែង-ទីតាំង</u>*

*មន្ទីរនីមួយៗ ត្រូវសង់ឆ្ងាយពីភូមិអ្នកស្រុក ក្បែរប្រភពទឹក មានស្ទឹង អូរ ត្រពាំង អណ្ដូងជាដើម នៅក្នុងព្រៃឈើស៊ុបទ្រុប និងនៅក្បែរវាលស្រឡះណាមួយ។ គេសង់ជាខ្ទមស្លឹកទាបនឹងដីនៅក្រោមដើមឈើធំៗ មានខ្ទមសំរាប់ធ្វើជាកន្លែងសំរាកដំណេក ខ្ទមសំរាប់ជាផ្ទះបាយនិងខ្ទមផ្សេងៗទៀតសំរាប់ជាកន្លែងធ្វើការ។ នៅក្នុងមន្ទីរឃោសនាភូមិភាគពិសេស មានពុម្ពអក្សរអង្គុលីលេខ ម៉ាស៊ីនទាញរ៉ូណេអូ ស្ដង់ស៊ីលទឹកខ្មៅរ៉ូណេអូ ឯកសារផ្សេងៗ ។ល។ នៅក្បែររោងធ្វើការ គេមានជីក បុងគ័រ (Bunker) និងលេណដ្ឋានតូចៗ ជាច្រើនសំរាប់ជ្រកនៅពេលយន្តហោះមកទំលាក់គ្រាប់បែក។ សមាជិកទាំងអស់ព្រមទាំងប្រជាជនចាស់ក្មេង សុទ្ធចេះស្ដាប់សំលេងយន្តហោះស៊ីនតែគ្រប់ធុន ដែលមានហោះ*

ហើរនៅក្នុងទឹកដីខ្មែរ។ គ្រាន់តែឮសូរពីចម្ងាយ ក្មេងៗ អាយុប្រមាណ ១០ ឆ្នាំក៏អាចដឹងបានភ្លាមថាជា យន្តហោះសង្កេតការណ៍ ឬយន្តហោះទំលាក់គ្រាប់បែក តេ-២៨។

មន្ទីរសំរាប់កម្មាភិបាល (ក្របខ័ណ្ឌ) សំខាន់ៗ ច្រើនសង់នៅក្នុងព្រៃស្ងាត់ពីភូមិតូចៗ ដែលជា ភូមិបង្អែក ឬភូមិមូលដ្ឋានរបស់គេប្រមាណ ១៥០០ ម៉ែត្រ។ តាមការសង្កេត ទីតាំងរបស់គេច្រើននៅ ក្នុងព្រៃឈើក្រាស់ផង នៅក្បែរវាលស្រែតូចៗ ផង ដើម្បីលាក់កំបាំងកុំឲ្យយន្តហោះមើលឃើញ និង ដើម្បីឲ្យមានខ្យល់អាកាសចេញចូលបរិបូរណ៍។

បក្សកុម្មុយនិស្តកម្ពុជាបានបែងចែកតំបន់ដែលគេកាន់កាប់ ជាភូមិភាគធំៗ ដូចតទៅ :

១- ភូមិភាគនិរតីទិស រួមបញ្ចូលខេត្តកំពត កោះកុង ក្រុងសីហនុ កំពង់សិលា តាកែវ កំពង់ឆ្នាំង កំពង់ស្ពឺ ឧដុង្គ និងខេត្តកណ្តាល ១ ភាគ។

២- ភូមិភាគបូព៌ាទិស រួមបញ្ចូលខេត្តក្រចេះ ស្វាយរៀង ព្រៃវែង កំពង់ចាម។

៣- ភូមិភាគពាយព្យទិស មានខេត្តកំពង់ធំ សៀមរាប ឧត្តរមានជ័យ បន្ទាយឆ្មារ។

៤- ភូមិភាគពោធិសាត់-បាត់ដំបង-ប៉ៃលិន។

៥- ភូមិភាគពិសេស (ទើបបង្កើតថ្មីនៅចុងឆ្នាំ ១៩៧១) សំរាប់ត្រួតត្រាតំបន់ជុំវិញភ្នំពេញ។ សព្វថ្ងៃនេះ ភូមិភាគពិសេសតាំងទីបញ្ជាការនិងទីចាត់ការរបស់ខ្លួន នៅក្នុងភូមិភាគនិរតីទិស ត្រង់ព្រំ ប្រទល់ខេត្តកំពង់ស្ពឺនិងកំពង់ឆ្នាំង ក្នុងសង្កាត់ពាមប្រាំបីមុម ប៉ែកខាងត្បូងក្នុងស្រុកកំពង់ត្រឡាច និង តាំងបុគ្គលិករដ្ឋបាលរបស់គេខ្លះទៀតនៅក្នុងខេត្តកំពង់ស្ពឺ (ស្រុកបរសេត) ក្នុងខេត្តកណ្តាល (ស្រុក កណ្តាលស្ទឹង-ស្រុកស្អាង-កោះធំ)

៦- ខេត្តព្រះវិហារ ស្ទឹងត្រែង មណ្ឌលគីរី និងខេត្តរតនគីរី ត្រូវបានគណៈមជ្ឈឹម (គណៈ កម្មការកណ្តាល) នៃបក្សកុម្មុយនិស្តខ្មែរគេបានកាន់កាប់ផ្ទាល់។ តាមផែនទីភូមិសាស្ត្រនិងយុទ្ធសាស្ត្រ យើងអាចយល់បានថា ហេតុដូចម្តេចបានជា <គណៈមជ្ឈឹម> គេសុខចិត្តកាន់កាប់ភូមិភាគទាំងអស់នេះ ផ្ទាល់។ ខេត្តទាំងអស់នេះជាមូលដ្ឋានយុទ្ធសាស្ត្រយ៉ាងធំ មានព្រំប្រទល់ជាប់ទៅនឹងយួន លាវ ថៃ។

ភូមិភាគនិមួយៗ មានចែកទៅជាតំបន់ ជាស្រុក ជាឃុំ ភូមិតទៅទៀត។ លេខាធិការ ឬប្រធាន ភូមិភាគនិមួយៗ មានឥទ្ធិពលខ្លាំងណាស់ទៅលើភូមិភាគរបស់ខ្លួន។ គឺជាអ្នកទទួលខុសត្រូវទាំងស្រុង ទៅលើអំណាចនយោបាយរដ្ឋបាល សេដ្ឋកិច្ច-សង្គមកិច្ច និងយោធា «លេខាភាគ» «ប្រធានភាគ» នេះ សុទ្ធតែជាសមាជិកនៅក្នុង «គណៈមជ្ឈឹម» ផង និងជាសមាជិកនៅក្នុងរាជរដ្ឋាភិបាលរួបរួមជាតិ កម្ពុជា» ( Le GRUNK ) ផង។ គឺជាបញ្ញវន្ត «ស្នូលខ្មែរក្រហម» ដើមចាស់ដែលធ្លាប់ «ជាប់នឹងចលនា កុម្មុយនិស្តខ្មែរ» ពីយូរមកហើយ ហើយជា «បក្ខជនពេញលេញ» នៅក្នុងបក្សរបស់គេ។

នៅភូមិភាគនិរតីទិស វរជនខ្មែរក្រហមសំខាន់ៗ មានលោក ជូ-ជេត ជាប្រធានភាគនិងជាអនុ រដ្ឋមន្ត្រីនៃក្រសួងសុខាភិបាល, លោក កោក-ឆាយ ហៅ ណាង ជាស្នងការនយោបាយនៅក្នុងកងទ័ព និរតីទិស, លោក ធុច-រិន ហៅ គ្រិន (អតីតសាស្ត្រាចារ្យមធ្យមសិក្សា) ជាប្រធានមន្ទីរវប្បធម៌ និង ឃោសនាការ, តាម៉ុក (ឈ្មោះបដិវត្តន៍) ជាមេបញ្ជាការកងទ័ពភូមិភាគនិរតីទិស។ ទីចាត់ការធំរបស់ គេនៅក្នុងតំបន់អមលាំង។ នៅទីនោះ មានរោងពុម្ពផ្សាយកាសែតមួយឈ្មោះ «ប្រជាជនបដិវត្តន៍» ដឹក

នាំដោយលោក ធុច-រិន ផ្ទាល់។ តំបន់ភូមិភាគនិរតីទិសនេះ មានទំហំធំជាងគេទាំងអស់ មានកំឡាំងទ័ពខ្លាំងជាងគេ និងមាន «ក្របខ័ណ្ឌ» ដឹកនាំសំខាន់ជាងគេ។

តាមសេចក្ដីរាយការណ៍របស់លោក កោគ-ឆាយ ផ្ញើជូនមហាសន្និបាតនៅចុងខែឧសភា ១៩៧២ ថាចំណាយក្នុងមួយខែៗ សំរាប់ភូមិភាគនិរតីទិស ឡើងដល់ជាង ២ លានរៀល សំរាប់បុគ្គលិករដ្ឋបាល និងយោធាខ្មែរក្រហមដែលត្រូវបានក្នុង ១ ខែ ១៣៥ រៀល ក្នុងបុគ្គលិកម្នាក់ៗ។

ភូមិភាគពិសេស នៅក្រោមការត្រួតត្រារបស់លោក សុក-ធួក ហៅ វន មានងារជាប្រធានភូមិភាគផង ជាអនុរដ្ឋមន្ត្រីក្រសួងសន្តិសុខជាតិផង។ បន្ទាប់មកទៀតមានមិត្ត ហង់ (ឈ្មោះបដិវត្តន៍) មិត្ត រស់-ជាទ្វោ ហៅ ជាតិ។

វរជនខ្មែរក្រហមសំខាន់ៗ នៅក្នុង «គណៈមជ្ឈិម» ច្រើនជាបញ្ញវន្តដែលបាត់ខ្លួនពីភ្នំពេញនៅចន្លោះឆ្នាំ ១៩៦២ និង ១៩៦៨ មានជាអាទិ៍ :

-លោក ខៀវ-សំផន ជាឧបនាយករដ្ឋមន្ត្រីក្រសួងការពារជាតិនៅក្នុងរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា និងជាអគ្គមេបញ្ជាការនៃ «កងកម្លាំងប្រដាប់អាវុធរំដោះជាតិកម្ពុជា»

-លោក សាឡុត-សរ (វរជនទី ១) ជាអគ្គលេខាធិការនៃបក្សកុម្មុយនិស្តកម្ពុជា

-លោក អៀង សារី ជាវរជនទី ២ នៅក្នុងបក្សកុម្មុយនិស្តខ្មែរ

-លោក សុន-សេន ជាវរជនទី ៤

-លោក កុយ-ធួន ជាអនុរដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ

-លោក ហ៊ូ-នឹម ជារដ្ឋមន្ត្រីក្រសួងឃោសនាការ

-លោក ទិវ-អុល ជាអនុរដ្ឋមន្ត្រីក្រសួងមហាផ្ទៃទទួលបន្ទុកខាងរៀបចំជនបទនិងសហករណ៍

-អ្នកស្រី ខៀវ ប៉ុណ្ណារី អនុរដ្ឋមន្ត្រីក្រសួងអប់រំជាតិ វប្បធម៌និងយុវជន

-លោក ជូ-ជេត អនុរដ្ឋមន្ត្រីក្រសួងសុខាភិបាល

-លោក សុក-ធួក អនុរដ្ឋមន្ត្រីក្រសួងសន្តិសុខជាតិ

-លោក ប៉ុក ឌើសកុមារ អនុរដ្ឋមន្ត្រីក្រសួងការបរទេស

លោក សុន-សេន និងលោក ប៉ុក ឌើសកុមារ ក្រោយពេលដែលអាជ្ញាធរយើងនៅភ្នំពេញផ្សាយថាបាត់ខ្លួនហើយ បានលាក់ខ្លួនសំងំនៅក្នុងក្រុងភ្នំពេញអស់រយៈពេលមួយឆ្នាំទៀត។ នេះជាពត៌មានដែលយើងបានទទួលពីវរជនខ្មែរក្រហមនៅក្នុងព្រៃ។

ចំពោះក្របខ័ណ្ឌខ្មែរក្រហមសំខាន់ៗ ដែលបានបាត់បង់ជីវិតនៅក្នុងព្រៃវិញ មានលោក អ៊ុច-វ៉ែន (សាស្ត្រាចារ្យ) ស្លាប់ដោយជម្ងឺគ្រុនពោះវៀន និងលោក ជី-គីមអាន (វិស្វករ) ស្លាប់ដោយធ្វើអត្តឃាតខ្លួនឯងនៅភូមិស្រែអណ្ដូង។

នៅក្នុងមន្ទីរឃោសនាការ យើងបានរស់នៅក្នុងរង្វង់សមមិត្តដែលមានទស្សនៈបដិវត្តន៍សង្គមនិយមចង្អៀតចង្អល់ និងឆ្លងហួសប្រមាណ។ សមាជិកទាំងនោះច្រើនជាយុវជនក្មេងៗ ធ្លាប់ជាសមាជិកនៅក្នុងសមាគមនិស្សិតខ្មែរ ( AGEK ) បំប៉នដោយប៉េកាំង។

មន្ទីរសិល្បៈភូមិភាគពិសេស ស្ថិតនៅប៉ែកនិរតីភូមិស្រែបុស្សី ចម្ងាយប្រមាណ ៦០០ ម៉ែត្រ។ មានយុវជនតូចៗ និងអ្នកដឹកនាំសិស្សទាំងអស់ជាង ៧០ នាក់នៅទីនោះ ដែលភាគច្រើនជាកូនកសិករ

មានខ្លះជាកូនចៅជនស្នូលខ្មែរក្រហម មានកូនលោក អៀង-សារី និងកូនលោក សៀង-ប៉ៅសែ ជាដើម។

នៅខាងកើតមន្ទីរឃោសនាការប្រមាណ ៣ គ.ម. គឺជាខាងលិចភូមិចុងគ្នោតប្រមាណ ៨០០ ម. មានមន្ទីរពេទ្យធំរបស់ភូមិភាគពិសេស សង់នៅមាត់អូរត្រង់ភូមិចាស់ដែលគេបោះបង់ចោល។ មន្ទីរពេទ្យនេះអាចឲ្យអ្នកជម្ងឺ អ្នករបួសមកដេកព្យាបាលបានរាប់រយនាក់។ គឺនៅក្នុងមន្ទីរពេទ្យនេះហើយដែលលោកវេជ្ជបណ្ឌិត ជួន-ជឿន, លោកវេជ្ជបណ្ឌិត ឌី-ផុន, លោកសាស្ត្រាចារ្យ យៀង-កាអុន និងលោកវិស្វករ ងួន-អេង នៅធ្វើការ អមដោយគ្រូពេទ្យខ្មែរក្រហមខ្លះទៀតដែលទើបមកពីហាណូយ។

មន្ទីរសេដ្ឋកិច្ចភាគ តាំងនៅភូមិតាំងខ្ទៅប្របមាត់ស្ទឹងប៉ែកពាយ័ព្យវត្តតាំងខ្ទៅ។ លោក សៀង-ប៉ៅសែ ទទួលខុសត្រូវលើសេដ្ឋកិច្ចភាគ លើរថយន្តប្រើប្រាស់ខ្លះៗ មានឡានទឡ្ងរ៉ូវ៉ែរ ឡានកាំមីញ៉ុងជាដើម។ នៅជាប់នឹងមន្ទីរសេដ្ឋកិច្ចភាគប៉ែកខាងត្បូង មានសង់រោងជាច្រើនសំរាប់ជួល «ក្មៀវចំណូលថ្មី» ដែលទើបរត់ចេញពីភ្នំពេញ ហើយដែលមានទិន្នាការនយោបាយត្រឹមក្របខ័ណ្ឌរណសិរ្ស (សីហនុនិយម)។ «ក្មៀវចំណូលថ្មី» ត្រូវបានអង្គការ «បន្ទុំសតិអារម្មណ៍» មួយកន្លែងសិន មិនសូវមានសេរីភាពចេញដើរហេតរហូតទេ ហើយក៏គ្មានទទួលភារកិច្ចអ្វីធំដុំពីអង្គការដែរ ក្រៅពីការកាប់គាស់ដី ដាំដំណាំ ឬចិញ្ចឹមមាន់-ទាបន្តិចបន្តួច សំរាប់ផ្គត់ផ្គង់ជីវភាពផ្ទាល់ខ្លួន។ សមាជិកនៅក្នុងមន្ទីរដទៃទៀតនិយមចំអកហៅទីកន្លែងនេះថា «ភូមិរណសិរ្ស»។ លោក ម៉ែន-ចូ និងលោក សៀង-ប៉ៅសែ ជាអ្នកមើលការខុសត្រូវ តាមដានមើលក្មៀវចំណូលថ្មី។ នៅទីនេះ យើងបានជួបពិភាក្សាជាមួយលោកសក្តិ ៤ នារីម្នាក់ឈ្មោះ សូ មេ៉ាម និងសហការីជាអនុសេនីយត្រី ២ រូបទៀត នៅនាថ្ងៃទី ១២ វិច្ឆិកា ១៩៧២។

## <u>វិន័យរបស់អង្គការ</u>

វិន័យរបស់អង្គការមានលក្ខណៈតឹងរឹងខ្លាំងណាស់។ គឺជាវិន័យរបស់កុម្មុយនិស្ត ដែលជាវិន័យរឹងដូចដែក ( Discipline de fer ) គេបានអប់រំ ផ្សាំង (Système de dressage ) យុវជននិងក្របខ័ណ្ឌរបស់គេឲ្យទៅជាជនកុម្មុយនិស្ត (Un communiste ) តាមក៏រិតតឹងរឹងខ្លាំងឡើងៗ ជាលំដាប់។ មានឯកសារច្រើនចងក្រងដោយ «គណៈមជ្ឈឹម» សំរាប់យកមកធ្វើជាគោលរៀនសូត្រ។

ចំពោះសមាជិកមន្ទីរ យុទ្ធជន ដែលនៅស្រឡាញ់ស្តេចសីហនុនៅឡើយ គេពុំទាន់ហ៊ានបើកមុខបង្ហាញទិសដៅពិតប្រាកដរបស់គេទេ។ គេយកតែត្រឹមគោលការណ៍ការតស៊ូក្នុងក្របខ័ណ្ឌរណសិរ្ស មកបង្ហាត់បង្រៀន មកអប់រំ គឺគោលការណ៍បដិវត្តន៍ប្រជាជាតិ (révolution nationale ) ។ គេបោកបញ្ឆោតថា ៖ «យើងតស៊ូធ្វើបដិវត្តន៍នេះ ដើម្បីរំដោះប្រជាជាតិពីនឹមចក្រពត្តិអាមេរិកាំង» ។

បន្តិចម្តងៗ គេរំកិលចូលទៅក្នុងទ្រឹស្តី បដិវត្តន៍ ប្រជាធិបតេយ្យ បំផុសការតស៊ូវណ្ណៈ ដែលជាទំនាស់ស្លាប់រស់នៅក្នុងវណ្ណៈ វណ្ណៈនៅក្នុងសង្គមកម្ពុជា។ គេវាយប្រហារពួកសក្តិភូមិ ពួកប្រតិកិរិយា ពួកនាយទុន គេមិនវាយប្រហារធំៗ ទេ តែគេមិនដែលបំផុស ឬលើកតំកើងម្តងណាទេ។ នៅក្នុងជួរក្របខ័ណ្ឌខ្មែរក្រហមខ្លះ គេវាយប្រហារ «ធាតុសក្តិភូមិ» របស់ស្តេចសីហនុដោយចំហរ។

ក្របខ័ណ្ឌខ្មែរក្រហមណាហ៊ានលើកសរសើរស្តេចសីហនុ នឹងត្រូវគេចាត់ទុកជាអ្នកប្រឆាំងនឹងបដិវត្តន៍របស់គេ។ គេនៅចាត់ទុកស្តេចសីហនុថាជានិមិត្តរូបនៃរបបសក្តិភូមិដដែល ថ្វីបើស្តេចសីហនុទៅនៅប៉េកាំងក៏ដោយ។

ជាមួយប្រជាជន មហាជន គោលវិន័យរបស់អង្គការខ្មែរក្រហមដែលសំខាន់ៗ ជាងគេគឺកុំធ្វើឲ្យប៉ះពាល់ដល់ «មាគ៌ាមហាជន» ខ្មែរក្រហមម្នាក់ៗ ត្រូវប្រកាន់អាកប្បកិរិយាទន់ភ្លន់ សុភាពរាបសារជាដាច់ខាតជាមួយប្រជាជន គេត្រូវកំទេចនិន្នាការទៅរក «អាជ្ញានិយម» ទៅរក «នាម៉ឺននិយម»។ គេបានរំលឹកជារឿយៗ នូវពាក្យរបស់ ម៉ៅ-សេទុង ថែងថា៖ «ប្រជាជនជាត្រី គេជាទឹក»។ ជនបដិវត្តន៍ (បដិវត្តន៍សង្គមនិយម) មួយរូបៗ ត្រូវទុកដាក់ខ្លួនជាកូនចៅប្រជាជន បំរើប្រជាជនឲ្យអស់ពីចិត្តពីថ្លើម ហើយត្រូវធ្វើខ្លួនឲ្យដូចប្រជាជន ដើម្បីរៀនសូត្រពីមហាជន ព្រោះ «មហាជនជាប្រភពនៃចំណេះវិជ្ជាដែលមិនចេះរីងស្ងួត»។ គេលើកជាពាក្យស្លោកថា «រៀនសូត្រពីមហាជន ដើម្បីមហាជន» តែគេបានប្រកាន់ជំហរមួយទៀតដែរថា «មិនត្រូវដើរតាមកន្ទុយមហាជនពេកទេ»។

ក្នុងការរស់នៅ ដេក ដើរ ស៊ីចុក ស្លៀកពាក់ គេប្រុងប្រយ័ត្នមិនឲ្យប្លែកពីប្រជាជន។ អាកប្ប-កិរិយា និងសំដីសំដៅទៅរកប្រជាកសិករ ត្រូវទន់ភ្លន់សុភាពរាបសារជាដរាប។ ហេតុយ៉ាងនេះហើយទើបបានជាខ្មែរក្រហមគេបង្ខំឲ្យស្លៀកពាក់ខ្មៅ បង់កក្រមា។ ម្ហូបអាហារប្រចាំថ្ងៃ ក៏មិនត្រូវសំបូរហូរហៀរឆ្ងាញ់ពិសារលើសប្រជាជនដែរ។ គេឧស្សាហ៍រំលឹកដល់សភាពក្រខ្សត់របស់ប្រជាជនដែលបានគាំទ្របដិវត្តន៍របស់គេ។ ម្យ៉ាងទៀត ការបង្ខិតបង្ខំមិនឲ្យ «ញាក់ទៅរកឆ្ងាញ់» នេះ ចូលជាយុទ្ធវិធីរបស់គេមួយ ដើម្បីទំលាប់គ្នាគេឲ្យចេះទ្រាំទ្រនូវការលំបាកសព្វបែបយ៉ាងផង និងអប់រំខ្លួនប្រាណនិងសតិអារម្មណ៍របស់គេឲ្យទៅជា «កម្មាជីព» ផង ( Prolétaire ) ។ ដូច្នេះហើយ បានជានៅតាមមន្ទីរនិមួយៗ គេកម្រមានកព្វវាសនាបានបរិភោគអាហារពីរមុខណាស់។

«អង្គការ» ខ្មែរក្រហមហាមប្រាមយ៉ាងតឹងរ៉ឹងមិនឲ្យប៉ះពាល់ដល់ទ្រព្យសម្បត្តិរបស់ប្រជាជន។ ការខូចខិលរំលោភលើកូនក្រមុំប្រជាជន នឹងត្រូវទទួលទោសជាទំងន់។ តាមការសង្កេតជាហូរហែមកថា វិន័យទាំងអម្បាលមាណ ត្រូវបានគេគោរពអនុវត្តន៍បានខ្ជាប់ខ្ជួននិងស័ក្តិសិទ្ធិមែន។

ចំណុចមួយទៀតដែលជា «សកម្មភាពចិត្តសាស្រ្ត» យ៉ាងស័ក្តិសិទ្ធិរបស់ខ្មែរក្រហមទៅលើប្រជាពលរដ្ឋកសិករ គឺជាការជួយទុក្ខធុរៈប្រជាកសិករ។ បើមានកសិករឈឺថ្កាត់នៅក្នុងភូមិ ជាពិសេសកសិករក្រ ពួកខ្មែរក្រហមគេឧស្សាហ៍នាំគ្នាទៅចាក់ ឬចែកថ្នាំឲ្យដល់ផ្ទះតែម្តង ទោះជាយប់ព្រលប់មានភ្លៀងផ្គរក្តី។ នៅរដូវភ្ជួររាស់ ដកស្ទូង ច្រូតកាត់ ឬបោកបែន មន្ទីរនិមួយៗ ត្រូវចាត់សមាជិកឲ្យទៅជួយធ្វើសឹងតែរាល់ពេល។ ការទៅចុះ «ជាប់នឹងប្រជាជន» ដើម្បី «បំរើប្រជាជន» ប្រស្រ័យទាក់ទងជិតស្និទ្ធនឹងប្រជាជន គឺជាការអនុវត្តន៍នូវទ្រឹស្តីមួយក្នុងការអប់រំពួកក្របខ័ណ្ឌខ្មែរក្រហម។

សកម្មភាពចិត្តសាស្រ្តរបៀបនេះ មានប្រសិទ្ធភាពនិងស៊ីជម្រៅទៅលើប្រជាជនពិតប្រាកដមែនជាជាងការណែនាំបង្រៀនទ្រឹស្តី។ ប្រជាជនកសិករនៅតាមភូមិមូលដ្ឋាន ដែលមិនយល់អ្វីសោះពីរឿងបដិវត្តន៍សង្គមនិយម ក៏ចាប់ស្រឡាញ់និងគាំទ្រអង្គការភ្លាមៗ តាមរយៈមនោសញ្ចេតនាស្និទ្ធិស្នាល។

*<u>នៅក្នុងមន្ទីរ</u>*

*នៅគ្រប់មន្ទីរទាំងអស់ ខ្មែរក្រហមរស់នៅជាសមូហភាព (* Collectivité) *) គោរពវិន័យរបស់សមូហភាព (វិន័យអង្គការ) គោរពពេលវេលាធ្វើការដែលសមូហភាពបានកំណត់អនុវត្តន៍ផែនការប្រចាំសប្តាហ៍ ប្រចាំខែ ដែលសមូហភាពបានលើកឡើង។*

*សមាជិកទាំងអស់នៅក្នុងមន្ទីរត្រូវធ្វើពលិកម្មដូចគ្នា ទាំងសមាជិកធម្មតា ទាំងប្រធាន។ កិច្ចការពលកម្មនេះត្រូវបានគេចាត់ទុកជាចាំបាច់ទីមួយ សំរាប់ «កសាង» ខ្លួនឲ្យទៅជាកម្មាជីព ជាកម្មករមានផ្ទត់ចង្វាក់ទៅរកពលកម្ម អាចទ្រាំទ្រនឹងការលំបាកផ្សេងៗ ដែលបដិវត្តន៍របស់គេអាចពើបប្រទះ។ កិច្ចការពលកម្មអាចដុសលាងសតិអារម្មណ៍បដិវត្តន៍មួយថ្មីគឺ សតិអារម្មណ៍បដិវត្តន៍ សតិអារម្មណ៍ជាកម្មាជីព សតិអារម្មណ៍សង្គមនិយម។ ពួកខ្មែរក្រហមឧស្សាហ៍ទូន្មានគ្នាគេថា៖ «បដិវត្តន៍របស់គេ នៅមានការបត់បែនលំបាកវេទនាតទៅទៀត»* (La révolution disait Mao Tsé Tung suit un chemin toujours tortueux ; jamais rectiligne) *សមាជិកម្នាក់ៗ មិនត្រូវជិះជាន់ពលកម្មរបស់គេទេ ពួកគេទាំងអស់ (លើកលែងវរជនខ្មែរក្រហមសំខាន់ៗ ខ្លះដែរ) ត្រូវដាំបន្លែ ដាំដំឡូង រែកទឹក ពុះអុស ធ្វើអង្ករដោយខ្លួនឯង តាមវេនវៀងៗ ខ្លួន។ ក្រៅពីកិច្ចការសំរាប់ជីវភាពមន្ទីរ សមាជិកម្នាក់ៗ មានភារកិច្ចចំពោះមុខដូចជាការងារនៅរោងពុម្ពជាដើម។ អង្គការហាមប្រាមមិនឲ្យប្រើពាក្យ «អា-មីង» រវាងគ្នានិងគ្នា។ គេយកពាក្យ «មិត្ត» មកប្រើសឹងតែទូទៅ។ ពាក្យបង មីង មា អ៊ុំ តា យាយ ក៏មានប្រើដែរ តែជាទូទៅគេប្រើពាក្យ មិត្ត ច្រើនជាង។ គេឧស្សាហ៍ទូន្មានឲ្យពង្រឹង «មនោសញ្ចេតនានយោបាយ» រវាងគ្នានិងគ្នាជាង «មនោសញ្ចេតនា» ជាបុគ្គល។*

*អង្គការធ្លាប់ណែនាំឲ្យខិតខំជំរុះ «ធាតុបុគ្គល» លក្ខណៈបុគ្គលនិយមដែលគេចោទថាជា «ធាតុប្រតិកិរិយា» ឲ្យបានជាអតិបរមា ឲ្យប្រកាន់ខ្ជាប់នូវ «ស្មារតីសួនរួម» នូវជំហរ «សមូហភាព» ឲ្យគិតប្រយោជន៍សួនរួមធំជាងប្រយោជន៍សួនតួ។ បើសមាជិកណាធាប់ញាក់ញោច ធាប់ខឹងឆេវឆាវ គេចោទថានៅមាន «ធាតុបុគ្គលក្រាស់»។ ជាធាតុបុគ្គលនេះគេច្រើនភ្ជាប់ «ធាតុសេរីនិយម» ជាមួយផង។ ធាតុទាំងអស់នេះត្រូវបានគេចាត់ទុកជាធាតុប្រឆាំងនឹងបដិវត្តន៍ ជាធាតុរបស់វណ្ណៈជិះជាន់ ធាតុរបស់ពួកប្រតិកិរិយា។ នៅក្នុងប្រជុំជីវភាពម្តងៗ គេតែងទិតៀនគ្នាទៅវិញទៅមកពីរឿង «សេរីនិយម» ក្នុងការ «ហូប ដេក ដើរ និយាយ» បានសេចក្តីថា មានមិត្តខ្លះបរិភោគបាយហួសពីការកំណត់របស់គេ ឬទំរន់ក្រក្រោកពីដំណេក ឬនិយាយហូរហែពេក មិនចេះរក្សាការណ៍សម្ងាត់ ។ល។*

*ការតាមដានគ្នាទៅវិញទៅមក ជាករណីកិច្ចនៃសមាជិកម្នាក់ៗ ហើយការជំរុះធាតុដូចពោលខាងលើនេះ ក៏ប្រយោជន៍អប់រំសមាជិករបស់គេឲ្យជា «ជនសង្គមនិយម»* (Un Socialiste)*។ នេះជាជំហាន «ផ្សាំង» មនុស្សឲ្យទៅជា «ម៉ាស៊ីន» មួយ* (Un robot, un automate) *ផ្ទុយពីដំណើរវិវត្តន៍ធម្ម-ជាតិ។*

*លក្ខណៈពាលា អាវ៉ាសែ ត្រូវអង្គការណែនាំឲ្យបំបាត់ មានរឿងស្រី ស្រា ល្បែងជាដើម។ ចំពោះស្រីនិងល្បែង ឃើញអង្គការខ្មែរក្រហមដោះស្រាយបានពិតប្រាកដមែន ជាមួយនឹងអំពើធក់ប្ចន់ផ្សេងៗ ។ ចំណែកគ្រឿងស្រវឹងនៅមានសេសសល់ខ្លះៗ តែអង្គការខ្មែរក្រហមបានដោះស្រាយបំបាត់លក្ខណៈស្រវឹង អាវ៉ាសែបានមួយកំរិតយ៉ាងធំ។*

*នូវក្នុងសង្គមរបស់ពួកខ្មែរក្រហម គេបានហាមប្រាមមិនឲ្យបុរសមានប្រពន្ធពីរដាច់ខាត។*

*កសិករនៅក្នុងភូមិ ក៏ដូចសមាជិកនៅក្នុងមន្ទីរមួយៗ ដែរ ត្រូវមានការកិច្ចតាមដានមើលសកម្មភាពគ្នាទៅវិញទៅមកនៅក្នុងពួកឬនៅក្នុងក្រុមរបស់ខ្លួន ដើម្បីអប់រំគ្នាទៅវិញទៅមកដែលពួកកុម្មុយ-និស្តនិយមហៅថា «កសាង»។ ក្នុងមួយសប្តាហ៍គេមានប្រជុំពួក ឬក្រុមម្តង គេហៅថាប្រជុំជីវភាព។ ក្នុងពេលប្រជុំពួកគេធ្វើការទិតៀន និងស្វ័យទិតៀនគ្នាទៅវិញទៅមក គឺគេលើកពីការខ្វះខាត ការខ្ចាំខ្ចង់ពីគុណសម្បត្តិ និងគុណវិបត្តិរបស់ខ្លួននិងមិត្តរួមពួកមកលាតត្រដាង។ គឺការធ្វើស្វ័យទិតៀននិងទិតៀននេះហើយ ដែលបង្ខំឲ្យពួកខ្មែរក្រហមឬអ្នកស្រុកតាមដានគ្នាទៅវិញទៅមក។ ការធ្វើស្វ័យទិតៀន និងទិតៀននេះហើយ ជាឧបករណ៍លេខមួយរបស់លទ្ធិម៉ាក្សិស្ត-ឡេនីនិស្ត។ គោលជំហរដែលសមាជិកម្នាក់ៗ ត្រូវត្រួតពិនិត្យទៅលើខ្លួនឯងនិងទៅលើមិត្តខ្លួនមាន :*

- *គោលជំហរពលកម្ម*
- *គោលជំហរនយោបាយ*
- *គោលជំហរសាមគ្គីភាព*
- *គោលជំហរសតិអារម្មណ៍*
- *គោលជំហរចាត់តាំង*

*ក្នុងឱកាសប្រជុំក្រុម គេត្រួតពិនិត្យគោលជំហររួមរបស់ក្រុមទាំងមូល មិនសំដៅទៅលើបុគ្គលណាម្នាក់ទេ។ ក្រោយការពិនិត្យជំហរផ្សេងៗរបស់ក្រុម គេចាប់រៀបចំធ្វើផែនការរួមសំរាប់អាទិត្យក្រោយ។*

*ក្នុងការទិតៀនស្វ័យទិតៀននេះ អង្គការខ្មែរក្រហមបានណែនាំទូន្មានមិនឲ្យយកការទិតៀនស្វ័យទិតៀននេះធ្វើជាអាវុធសំរាប់សង់សឹកគ្នា វាយប្រហារគ្នាទេ។ គេទូន្មានឲ្យយកការទិតៀនស្វ័យទិតៀននេះ ធ្វើជាមធ្យោបាយអប់រំកែគ្នាទៅវិញទៅមក ធ្វើជា «ថ្នាំកំចាត់រោគ» ផ្សេងៗ មានរោគ «បុគ្គលនិយម សេរីនិយម នាម៉ឺននិយម អាជ្ញានិយម ការិយាល័យនិយម» ជាដើម។ អ្នកធ្វើការទិតៀនគេ និងអ្នកដែលត្រូវគេទិតៀន ត្រូវឲ្យមាន «ខួរក្បាលត្រជាក់ជានិច្ច» កុំញាក់ញោចខឹងឆេវឆាវ។ ការធ្វើស្វ័យទិតៀននិងទិតៀនត្រូវឈរលើអង្គការនិងមាគ៌ាមហាជនជានិច្ច។*

*វិន័យមួយទៀតរបស់ខ្មែរក្រហម (ពួកក្របខ័ណ្ឌ) គឺការលាក់ការណ៍សំងាត់។ សមាជិកមន្ទីរត្រូវលាក់អាថិកំបាំងរបស់ខ្លួន របស់មន្ទីរ និងរបស់អង្គការ។ ហេតុដូច្នេះហើយបានជាម្នាក់ៗ ត្រូវមានឈ្មោះថ្មីមួយ ត្រូវលាក់ឈ្មោះដើមរបស់ខ្លួនកុំឲ្យនរណាដឹង លើកលែងតែអង្គការថ្នាក់លើគេត្រូវការសួរពត៌មានពីខ្លួនឯងជាផ្លូវការ។ ប្រសិនបើមានអ្នកដទៃណា ទោះជាអ្នកនៅក្នុងជួរដូចគ្នា ឬបងប្អូនកសិករណាចង់ដឹងពីទីតាំងរបស់មន្ទីរ ពីឈ្មោះដើម «វណ្ណភាព» ដើម ស្រុកកំណើតរបស់ខ្លួន គេមិនត្រូវប្រាប់ឲ្យនរណាដឹងទេ វិន័យនេះត្រូវបានគេរំលឹករាល់សប្តាហ៍និងតាមដានដូចសកម្មភាពផ្សេងៗទៀតដែរ។*

*ក្នុងរឿងឋានានុក្រម គេក៏បានអនុវត្តដោយហ្មត់ចត់ គឺអង្គការថ្នាក់ក្រោមគោរពអង្គការថ្នាក់លើគណៈភូមិស្តាប់បញ្ជាគណៈឃុំ គណៈឃុំស្តាប់បង្គាប់គណៈស្រុក គណៈស្រុកគោរពគណៈតំបន់ គណៈតំបន់គោរពគណៈភាគ គណៈភាគត្រូវស្តាប់គណៈមជ្ឈិម (គណៈកម្មការកណ្តាលនៃបក្សកុម្មុយនិស្តកម្ពុជា)។*

សមាជិកម្នាក់ៗ ត្រូវប្រគល់ខ្លួនឲ្យអង្គការ «កសាង» ដោយគ្មាន «តំលៃ» ត្រូវទុកចិត្តទាំងស្រុងទៅលើ «អង្គការ» ព្រោះអង្គការមានភ្នែកដូច «ម្នាស់» មិនចេះខុសឆ្គងៗ នេះជាលក្ខខ័ណ្ឌផ្តាច់ការរបស់បក្សទៅលើបុគ្គល បញ្ជាក់នូវអំណាចគ្មានព្រំដែនរបស់បក្សទៅលើអ្វីៗទាំងអស់ៗ គឺជាជំហានឆ្ពោះទៅរកលទ្ធិ «ផ្តាច់ការរបស់វណ្ណៈអធន» (Dictature prolétarienne) សមាជិកម្នាក់ៗ មានការទុកចិត្តទាំងស្រុងទៅលើអង្គការ ត្រូវការពារកិត្តិយសអង្គការ មិនត្រូវវាយប្រហារអង្គការពីក្រោយខ្នងឡើយៗ ប្រសិនបើអនុវត្តតាមមាគ៌ារបស់អង្គការហើយ តែបែរជាបានលទ្ធផលអាក្រក់ផ្ទុយទៅវិញ គេមិនត្រូវចោទប្រកាន់អង្គការថា «ដាក់ទិស» ខុសទេ គេត្រូវដាក់កំហុសទៅលើបុគ្គលទៅវិញ គឺបុគ្គលទេដែលមានការខ្ពាំខ្ពង់ មានការខ្វះខាតៗ ផលវិបាកមួយចៀសវាងមិនផុត គឺតែងតែលេចក្របខណ្ឌខ្មែរក្រហមណាម្នាក់បានប្រព្រឹត្តរំលោភលើវិន័យ ឬក្តោបអំណាចលើខ្លួនឯង ហើយយកឈ្មោះអង្គការមកធ្វើជាឡប់ឡែៗ ដែលហៅថាអង្គការ គឺបក្សកុម្មុយនិស្តកម្ពុជា និងសាខាតូចធំរបស់បក្សនេះ មានតាំងពីគណៈកម្មាការភូមិ ឃុំ ស្រុក តំបន់ ភាគ រហូតដល់ថ្នាក់មជ្ឈិម

វាំងមន្ទីរមួយនិងមន្ទីរមួយ គេហាមប្រាមមិនឲ្យចេញចូលរហេតរហូតទេ ពុំនោះទេ សមាជិកនោះនឹងត្រូវគេលើកយកមកទិតៀន «កសាង» ពីបទ «សេរីនិយម» ពីបទបំពានលើលក្ខខ័ណ្ឌការណ៍សំងាត់ៗ

ហេតុដូច្នេះហើយ បានជាសមាជិកនៃមន្ទីរនិមួយៗ ពុំសូវមានការទាក់ទងគ្នា ឬរយោបល់គ្នាទៅវិញទៅមកៗ គេរៀបចំយ៉ាងនេះ គឺដើម្បីខ្ទប់កំឡាំងអាចិកំបាំងបំរុងក្បត់អង្គការរបស់គេដែរៗ ក្នុងការរស់នៅតាមមន្ទីរនិមួយៗ គេឧស្សាហ៍រំលឹកឲ្យប្រកាន់ «ជំហរឯករាជម្ចាស់ការ ខ្លួនទីពឹងខ្លួន គឺមន្ទីរនិមួយៗ ត្រូវរកមធ្យោបាយដើម្បីរស់ដោយខ្លួនឯង»ៗ អង្គការគ្រាន់តែផ្តល់ប្រាក់ជីវភាពឲ្យក្នុង ១ ខែ ១៣៥ រៀល សំរាប់សមាជិកម្នាក់ៗ ៗ មន្ទីរនិមួយៗ ត្រូវលៃលកម្ហូបចំណី (ច្រើនតែក្តាមខ្យង) បន្លែខ្លួនឯង ត្រូវ «សំរុកបង្កបង្កើនផល» តាមកំឡាំងផ្ទាល់ខ្លួន ត្រូវចិញ្ចឹមមាន់-ទា ជ្រូក នៅតាមមន្ទីររៀងៗខ្លួនតាមលទ្ធភាពដែលអាចធ្វើទៅបានៗ

<u>កិច្ចការពលកម្ម</u>

កិច្ចការពលកម្មនេះ ត្រូវបានអង្គការចាត់ទុកជាករណីកិច្ចទី១ របស់សមាជិកម្នាក់ៗៗ ជនកុម្មុយនិស្តត្រូវតែ «លត់ដំ» ខ្លួននៅក្នុងការងារពលកម្មជាចាំបាច់ៗ ការងារពលកម្មសំរាប់ពួកក្របខ័ណ្ឌបញ្ញវន្ត មានលំនាំដូចគ្នានឹងការងាររបស់អ្នកស្រុក គឺៈ

- នៅក្នុងមន្ទីរ សមាជិកម្នាក់ៗ ទោះប្រុសក្តី ស្រីក្តី ជាបញ្ញវន្តក្តី ជាកូនកសិករសុទ្ធសាធក្តី ត្រូវរែកទឹក រកអុស ដាំស្ល បោសសំអាតទីធ្លាមន្ទីរ ជីកក្តាមតាមវាលស្រែ រែកទឹកស្រោចបន្លែ កិនស្រូវ ជាន់អង្ករ ឲ្យបាយមាន់-ទា ជ្រូក ដូចគ្នាទាំងអស់ៗ កិច្ចការទាំងអស់នេះ គេចែកវេនគ្នាធ្វើដោយទៀងទាត់ គ្មានអារម្មណ៍ចង្អៀតចង្អល់អ្វីទេៗ ការមើលបំណាំគ្នា ឬប្រកែកជំទាស់មិនព្រមធ្វើ មិនសូវមានទេៗ ម្នាក់ៗត្រូវសំដែងទឹកចិត្តអំណត់រៀងៗខ្លួន ក្នុងពេលបំពេញកិច្ចការពលកម្មអ្វីមួយៗ សមាជិកម្នាក់ដែលខ្ជិលច្រអូស ទំរន់ក្នុងកិច្ចការងារទាំងអស់នេះ នឹងត្រូវសមាជិកដទៃទៀតធ្វើការទិតៀននៅក្នុងពេលប្រជុំពួក ឬប្រជុំក្រុមៗ

- ការងារបង្កបង្កើនផល មន្ទីរនិមួយៗ ត្រូវបានអង្គការថ្នាក់លើណែនាំឲ្យចេះដោះស្រាយបញ្ហាជីវភាពដោយខ្លួនឯង កុំសូវពឹងផ្អែកលើប្រជាកសិករពេក ព្រោះប្រជាជនមានការខ្វះខាតច្រើនៗ មន្ទីរនិមួយៗ គាស់រានធ្វើចំការច្បារដំណាំដោយខ្លួនឯង មានដាំស្ពៃ ប៉េងប៉ោះ ជី ត្រកួន ឃ្លោក ត្រឡាច ត្រប់ ម្ទេស ដំឡូង ពោត សណ្តែកជាដើមៗ មានក្រុមខ្មែរក្រហមខ្លះទៀត ដូចជាមន្ទីរសិល្បៈភូមិភាគពិសេសជាដើម យុវជនក្មេងៗនាំគ្នាឡើងចង់ត្នោតយកទឹករំងាស់ធ្វើស្ករ សំរាប់ប្រើប្រាស់នៅក្នុងមន្ទីររបស់ខ្លួនៗ

ក្នុងរឿងចិញ្ចឹមមាន់-ទា ជ្រូកវិញ ក៏មន្ទីរទាំងអស់ប្រឹងប្រែងពង្រីកណាស់ដែរៗ ថ្វីបើមាន់-ទា ជ្រូកមាននៅតាមមន្ទីរក៏ដោយ ម្ហូបអាហារក៏នៅតែអត្តៈខាត់ ខ្សត់ខ្សោយដដែល ព្រោះម្យ៉ាង អង្គការណែនាំឲ្យ «ចេះសន្សំសំចៃ» ចេះអត់ទ្រាំនឹងការអត់ឃ្លាន ឲ្យបំបាត់«អារម្មណ៍»ចង់ឆ្ងាញ់ៗ ម្យ៉ាងទៀត ភូមិភាគដែលយើងរស់នៅ ជាភូមិភាគក្រខ្សត់ខាងត្រីសាច់ខ្លាំងណាស់ សូម្បីតែកង្កែបក៏ពិបាករកទៀតផងៗ ពងទា ២-៣ ត្រូវយកទៅស្ងោរជាមួយបន្លែស្ពៃ សំរាប់សមាជិក ១២ នាក់ៗ មានពេលខ្លះគេស្ងោរបន្លែទទេ គ្មានត្រីសាច់អ្វីទេៗ ក្នុងមួយឆ្នាំៗ មានខ្មែរក្រហមខ្លះបានបរិភោគត្រីស្រស់តែ ៣-៤ ដងប៉ុណ្ណោះទេ ហើយពុំបានគ្រប់គ្រាន់ទៀតៗ

- ការងារបំរើប្រជាជន ខ្មែរក្រហមម្នាក់ៗត្រូវជ្រួតជ្រាបនឹង «ទស្សនៈមហាជន» ត្រូវជាប់នឹងមហាជន ជាប់នឹងប្រជាជនៗ ការជួយធុរៈប្រជាជន ជាពិសេសប្រជាជនមូលដ្ឋាន ជាការយកចិត្តទុកដាក់ទី១ របស់អង្គការថ្នាក់លើៗ ពេលណាប្រជាជនលើកទំនប់ ជីកស្រះ ធ្វើថ្នល់ ឬសង់ផ្ទះ ពួកខ្មែរក្រហមដែលនៅជិតខាងភូមិនោះ តែងចាត់វេនគ្នាទៅជួយធ្វើ ហើយធ្វើដោយយកចិត្តទុកដាក់ទៀតផងៗ ពេលដកស្ទូង ច្រូតកាត់ បោកបែន គេក៏ផ្លាស់វេនគ្នាទៅជួយដោយទៀងទាត់ៗ ចំពោះកសិករណាដែលក្រខ្សត់ជាងគេ អង្គការក៏បានជួយធុរៈច្រើនជាងគេផងដែរៗ

នេះជាទិដ្ឋភាពមួយដែលយើងគួរចាប់អារម្មណ៍ៗ អង្គការខ្មែរក្រហមចាត់ទុកការងារពលកម្មជាជំហរទីមួយ ក៏ក្នុងគោលបំណង:

១- ឲ្យក្របខ័ណ្ឌសមាជិករបស់គេគ្រប់ជាន់ថ្នាក់ ត្រៀមខ្លួនចំពោះការពិបាកផ្សេងៗទៅថ្ងៃក្រោយ ឲ្យមានទំលាប់ស្រឡាញ់ការងារពលកម្មនេះ ដែលជាគោលការណ៍សំខាន់សំរាប់ឈានទៅកសាងប្រជាជាតិសង្គមនិយម ( Une nation socialiste ) ។

២- ឲ្យសមាជិកនិងក្របខ័ណ្ឌរបស់គេជិតស្និទ្ធនឹងប្រជាជន ស្គាល់សំណូមពរ និងទុក្ខធុរៈប្រជាជន ព្រមទាំងឆ្លៀតរៀនសូត្រពីប្រជាជនៗ នៅលើផ្នែកបច្ចេកទេសនៃការងារ «ប្រជាជនជាប្រភពនៃចំណេះវិជ្ជាមិនចេះរីងស្ងួត»ៗ

៣- បណ្តុះផ្នត់ស្មារតីគោរពអង្គការវិន័យរបស់ពួក របស់ក្រុម តាមលំនាំវិន័យសម្ភារៈនិយម ( Discipline matérialiste) របស់ពួកកម្មកររោងចក្រៗ

៤- ឲ្យសមាជិក ឬក្របខ័ណ្ឌម្នាក់ៗ ខំ «លត់ដំ» ខ្លួនដើម្បីជំរុះ «ធាតុ» មិនបដិវត្តន៍ មិនកម្មាជីព ដូចជា «ធាតុ» របស់បញ្ញវន្តភាគច្រើនជាដើមៗ បើ

មិនបានជាប់ខ្លួននឹងពលកម្មទេ បុគ្គលនោះពុំចេះស្រឡាញ់ប្រជាជនទេ នៅតែមានសតិអារម្មណ៍ជិះជាន់ពលកម្មរបស់អ្នកដទៃ ដែលជាសតិអារម្មណ៍របស់ពួកប្រតិកិរិយា របស់សក្តិភូមិ របស់ពួកមូលធន។

តាមទ្រឹស្តីសម្ភារៈនិយម មានតែពួកកម្មករ-កម្មាជីពទេ ដែលជាអ្នកកសាងពិភពលោក កសាងសង្គមនិយមនិមួយៗ។ វណ្ណៈកម្មករនិងកម្មាជីពនេះ មានការចំណាយច្រើនជាងគេទាំងអស់ នៅក្នុងសង្គមនិយមនិមួយៗ ។ ដូច្នេះ តាមលក្ខណៈប្រជាធិបតេយ្យ មិនគួរឡើយរដ្ឋអំណាចមិនបានធ្លាក់ទៅលើកណ្តាប់ដៃរបស់វណ្ណៈនេះ។ នេះជាទស្សនៈរបស់ពួកម៉ាក្សិស្ត-ឡេនីនិស្ត។

៥- បណ្តុះស្មារតីសម្ភារៈនិយម ប្រាកដនិយម វិទ្យាសាស្ត្រនិយម តាមគន្លងម៉ាក្សិស្ត-ឡេនីនិស្ត បំបាត់ទស្សនៈគំនិតនិយម ( Idéalisme ) ដែលបំរើវណ្ណៈប្រតិកិរិយា វណ្ណៈជិះជាន់ (នេះជាទស្សនៈរបស់ពួកខ្មែរក្រហម)។ ម្យ៉ាងទៀត ការងារពលកម្មនេះជាឱសថមួយ ជួយបំបាត់សតិអារម្មណ៍ ឬទស្សនៈចង្អៀតចង្អល់ផងដែរ (Etroitesse de vue )។

# ការអប់រំនយោបាយ

ខ្មែរក្រហមមានការចាប់អារម្មណ៍ខ្លាំងណាស់ ទៅលើការអប់រំនយោបាយ។ កំឡាំងនយោបាយជាកំឡាំងទីមួយរបស់គេ កំឡាំងយោធាគ្រាន់តែជាឧបករណ៍នៃកំឡាំងនយោបាយ។ សមាជិកខ្មែរក្រហមគ្រប់ក្របខ័ណ្ឌ ត្រូវទទួលការអប់រំនយោបាយជាចាំបាច់។ គេរៀនសូត្រនៅតាមសាលារៀននយោបាយ នៅតាមមន្ទីរ ពេលធ្វើមីទីង ធ្វើសន្និបាត ពេលប្រជុំជីវភាពជាដើម។

ការអប់រំនៅតាមសាលារៀននយោបាយ អង្គការខ្មែរក្រហមសព្វថ្ងៃនៅខ្វះកម្មាភិបាល «ក្របខ័ណ្ឌ» ប្រកបដោយគុណសម្បត្តិ និងវប្បធម៌នយោបាយច្រើនណាស់។ លោក ហ៊ូ-យន់ ខ្លួនឯងក៏បានសារភាពរឿងនេះនៅក្នុងមហាសន្និបាតបញ្ញវន្តនៅចុងខែឧសភា ១៩៧២ ផងដែរ។ កម្មាភិបាលម្នាក់ៗមុននឹងទៅកាន់នាទីទទួលខុសត្រូវណាមួយ ត្រូវទទួលការហ្វឹកហ្វឺនអប់រំអស់ពេលដ៏យូរ ពីមួយឆ្នាំទៅបីឆ្នាំយ៉ាងតិច ហើយធ្លាប់បំរើចលនារបស់គេយូរមកហើយផង នៅ «យុវកក» (យុវជនកុម្មុយនិស្តកម្ពុជា) ឬនៅក្នុង «សនកប» (សមាគមនារីកម្ពុជាប្រជាធិតេយ្យ)។

កម្មាភិបាលម្នាក់ៗ ត្រូវមានសីលធម៌រស់នៅ និងសីលធម៌នយោបាយស្អាតស្អំ គឺ :

១- ស្រឡាញ់ គោរព និងបំរើប្រជាជន-កម្មករ-កសិករឲ្យអស់ពីចិត្តពីថ្លើម មិនប្រើអំណាចផ្តាច់ការទៅលើប្រជាជន មិនគំរាមកំហែងប្រជាជន ត្រូវសុភាពរាបសារទន់ភ្លន់ទៅរកប្រជាជនជានិច្ច។

២- ស្មោះត្រង់និងការពារផលប្រយោជន៍ប្រជាជនជាដាច់ខាត មិនធ្វើអ្វីឲ្យប៉ះពាល់ដល់ទ្រព្យសម្បត្តិប្រជាជន សូម្បីតែម្ទេស ១ ផ្លែ ឬអង្ករ ១ កំប៉ុងក៏ដោយ មិនគំរាមកំហែងយកទ្រព្យសម្បត្តិប្រជាជន ទោះជាតាមមធ្យោបាយក្តៅ ឬត្រជាក់ក៏ដោយ។ មិនត្រូវស៊ីសំណូកសូកប៉ាន់ពីប្រជាជន។

៣- បើធ្វើអ្វីខុសចំពោះប្រជាជន ត្រូវសុំទោសប្រជាជន។

៤- និយាយស្តី ដេក ដើរ ឈរ អង្គុយ ស៊ីចុក លេងសើចដោយសុភាពរាបសារតាមប្រពៃណីប្រជាជន។

៥- កុំប្រព្រឹត្តអំពើល្មើសចំពោះនារីភេទ។

៦- កុំស៊ីផឹកអ្វីដែលមានលក្ខណៈ ពាលាអាវ៉ាសែ មិនបដិវត្តន៍។

៧- កុំលេងល្បែងស៊ីសងឲ្យសោះ។

៨- កុំប៉ះពាល់លុយកាក់ ទ្រព្យសម្បត្តិរួម របស់ប្រជាជន របស់អង្គការ។

៩- ត្រូវមានកំហឹងធាបចេះចំពោះខ្មាំង។

១០- ត្រូវធ្វើពលកម្មដូចប្រជាជន។

១១- ត្រូវគោរពមតិរបស់សមូហភាព អង្គការជានិច្ច។ មិនត្រូវធ្វើការតាមរបៀបផ្តាច់ការរបស់បុគ្គលម្នាក់ឡើយ។

១២- ត្រូវធ្វើការទិតៀននិងស្វ័យទិតៀនឲ្យបានល្អជានិច្ច ក្នុងអង្គការរណសិរ្ស ដោយស្មារតីស្មោះត្រង់ ចងកសាងសាមគ្គីភាព ឯកភាពផ្ទៃក្នុងឲ្យបានរឹងប៉ឹងជាលំដាប់ មិនត្រូវវាយប្រហារគ្នាក្រៅអង្គការ ឬចាក់ចុចដណ្តើមឥទ្ធិពលគ្នាឡើយ។

១៣- ត្រូវមានស្មារតីភ្ញាក់រលឹក ធ្វើបដិវត្តន៍ដោយខ្លួនឯង មិនត្រូវពឹងផ្អែកលើអ្នកដទៃ ឬបរទេស ឲ្យគេធ្វើជំនួសខ្លួនឡើយ។ ត្រូវយល់ឲ្យច្បាស់ថា បដិវត្តន៍នេះជាបដិវត្តន៍របស់ប្រជាជនកម្ពុជា ត្រូវតែប្រជាជនកម្ពុជាធ្វើដោយខ្លួនឯង និងកាន់កាប់វាសនាប្រទេសជាតិដោយខ្លួនឯង មិនដេកពឹងពាក់បរទេសធ្វើជំនួសទេ។

១៤- ត្រូវមានស្មារតីម្ចាស់ការ ចេះដោះស្រាយគ្រប់បញ្ហាដែលទាក់ទងដល់ជីវភាពខាងស្មារតី ខាងសំភារៈរបស់ប្រជាជន។

១៥- ត្រូវជឿជាក់ថា ការតស៊ូរបស់យើងមានការលំបាកមែន តែដាច់ខាតនឹងមានជ័យជំនះ។

នៅក្នុងសាលាអប់រំនយោបាយនេះ អង្គការខ្មែរក្រហមបានប្រើល្បិចដោយប៉ិនប្រសប់ ចេះលើកយកឯកសារនយោបាយនានា មកណែនាំអប់រំ សំរបទៅតាមកំរិតគំនិតនយោបាយរបស់សមាជិកម្នាក់ៗ (គេនិយមនិយាយថាការភ្ញាក់រលឹកនយោបាយ) បានសេចក្តីថា ចំពោះសមាជិកណាដែលនៅជំពាក់ចិត្តនឹងស្តេចសីហនុ (ក្របខ័ណ្ឌរណសិរ្ស) នៅឡើយ ហើយនៅខ្វាចរបបសង្គមនិយម គេច្រើនលើកយកតែឯកសារត្រឹមកំរិតរណសិរ្សមកអប់រំ ឬមួយក៏គេទុកឲ្យសមាជិកប្រភេទនេះ ទទួលការណែ

នាំហ៊ឹកហ៊ឺនទៅតាមមន្ទីរតែប៉ុណោះៗ បន្តិចម្តងៗ គេបំផុសមាគាំផ្តោះទៅរកទ្រឹស្តីក្រហម តាមរយៈឯកសារផ្សេងៗ មានជាអាទិ៍ ឯកសារស្តីពី :

-ការបែងចែកវណ្ណៈនៅក្នុងសង្គមកម្ពុជា
-ការតស៊ូវណ្ណៈ
-ទស្សនៈមហាជន
-ការកសាងជំហារកម្មាជីព
-ទិតៀន និងស្វ័យទិតៀន
-មោទនភាពខុស និងត្រូវ
-គុណសម្បត្តិរបស់កម្មាភិបាល ។ល។

ចំពោះក្របខ័ណ្ឌពេញលក្ខណៈ (កម្មាភិបាលស្នូល ដែលជា«បក្ខជននៃបក្សកុម្មុយនិស្តកម្ពុជា» Membre du parti communiste khmer) ក៏រិតអប់រំរៀនសូត្រក៏កាន់តែមានជំហារទៅទៀត គឺទៅរកផ្នត់សង្គមនិយម (Pli socialiste) ទៅរករបបកុម្មុយនិស្ត ហើយការអប់រំរៀនសូត្ររបស់ពួកប្រភេទនេះ ត្រូវទុកជាការលោក់កំបាំងមិនឲ្យសមាជិកប្រភេទណាសិរ្យ ប្រភេទសាមញ្ញដឹងឮឡើយ។ គឺកម្មាភិបាលជាបេក្ខជននេះហើយដែលអង្គការខ្មែរក្រហមចាត់ឲ្យទៅធ្វើជាស្នូលនៅតាមតំបន់នានា ជាប្រធានមន្ទីរ ជាស្នងការនយោបាយនៅក្នុងកងទ័ពគេ។

នៅភូមិភាគពិសេសរបស់អង្គការខ្មែរក្រហម អ្នកដែលមានភារៈបង្រៀនអប់រំក្របខ័ណ្ឌនយោបាយ មានលោក សៀង-ប៉ោសែ, លោក រស់-ជាទ្វោ, លោក សុក-ធួក, លោក ជី-គីមអាន (ទើបនឹងស្លាប់ដើមខែមេសា ១៩៧២), និងមិត្ត ហង់ (ឈ្មោះបដិវត្តន៍)។

នៅភូមិភាគនិរតីទិស មានលោក ជូ-ជេត, លោក កោត-ឆាយ, លោក ធុច-រិន ជាអ្នកបង្រៀន។

ការអប់រំនិងការរៀនសូត្រនៅតាមមន្ទីរ, មន្ទីរនិមួយៗ, ប្រធាននិងអនុប្រធានជាអ្នកដឹកនាំរៀនសូត្រ ពិភាក្សាពីគោលការណ៍ផ្សេងៗ ដែលមានចែងនៅក្នុងឯកសារ។ ឯកសារទាំងអស់ដែលគេយកមករៀនសូត្រ សុទ្ធតែតាក់តែងចេញពីគណៈកម្មការកណ្តាលនៃបក្សកុម្មុយនិស្ត (មជ្ឈិម) របស់គេ។ ការរៀនសូត្រនៅតាមមន្ទីរពុំបានធ្វើដោយទៀងទាត់ទេ ជួនគេរៀបចំធ្វើមួយខែម្តង ជួនពីរខែម្តង តាមពេលទំនេរ។

ក្រៅពីការរៀនសូត្រនៅក្នុងឯកសារ គេចាត់ទុកការប្រជុំជីវភាព (ប្រជុំធ្វើទិតៀន និង ស្វ័យទិតៀន) ដែលមានធ្វើរៀងរាល់ថ្ងៃអាទិត្យ ការអប់រំនយោបាយ និងការត្រួតពិនិត្យនូវការអនុវត្តន៍ទ្រឹស្តីមាគ៌ានយោបាយមួយយ៉ាងវិសេសវិសាល។ នៅក្នុងការប្រជុំទិតៀន និងស្វ័យទិតៀន ច្រើនរិះគន់គ្នាទៅវិញទៅមកពីធាតុ «បុគ្គលនិយម» ធាតុ «សេរីនិយម» ច្រើនជាងគេ។ គេខិតខំបំបាត់ «ធាតុ» ទាំងនេះ ក៏នៅក្នុងគោលដៅ «ផ្សាំង» មនុស្សឲ្យទៅជាឧបករណ៍មួយសំរាប់គោរពនិងអនុវត្តវិន័យរបស់អង្គការដោយគ្មានរអ៊ូរទាំ ដូចម៉ាស៊ីន សំរាប់របបសង្គមនិយមនេះឯង។ គេបណ្តុះផ្នត់គំនិតគោរពចង្វាក់វិន័យ ចង្វាក់ការងារ ចង្វាក់ជីវភាព ស្របតាមវិន័យរបស់កម្មករដែលគេតែងតែលើកយកមកធ្វើជាគំរូ។

គឺគេអនុវត្តទ្រឹស្តីកម្មាជីវបនីយកម្ម ដោយយកទំងន់អំណាចបក្សមកគ្របសង្កត់បន្តិចម្តងៗ។ នេះគឺជាវគ្គដំបូងនៃ «អំណាចផ្តាច់ការវណ្ណៈកម្មាជីព» (Phase primaire de la dictature prolétarienne)។

ការអប់រំនយោបាយតាមរយៈមីទីង យើងបានដឹងហើយថា មីទីងជាសាលាអប់រំនយោបាយមួយយ៉ាងសំខាន់នៃពួកសង្គមនិយម។ មេដឹកនាំខ្មែរក្រហមបានបើកមុខ «យីហោ» របស់គេជាសាធារណៈ។

នៅលើបដាក្រហមព្រោងព្រាត គេចែងពាក្យស្លោកផ្សេងៗ បញ្ជាក់នូវតួនាទីដឹកនាំរបស់ «បក្ស» មានជាអាទិ៍:

«មានតែបក្សកុម្មុយនិស្តកម្ពុជាទេ ដែលអាចដឹកនាំបដិវត្តន៍ទៅរកជ័យជំនះជាស្ថាពរបាន»។

«បក្សកុម្មុយនិស្តកម្ពុជាប្រកាន់នាទីដឹកនាំបដិវត្តន៍កម្ពុជា»។

ថ្ងៃ ៣០ កញ្ញា ១៩៧២ នៅវេលាម៉ោង ៧ ល្ងាច នៅខាងជើងភូមិតាំងខ្មៅ ក្រោមដំណក់ភ្លៀងស្រិចៗ ឧត្បោសនស័ព្ទបានបំពងបញ្ជាខ្លាំងៗ ឲ្យមិត្តទាំងអស់ទំលាក់ដៃអាវ បិទឡេវក ដោះមួក ប្រុងប្រៀបគោរព «ទង់បក្ស» ទស្សនិកជនគោរពតាមបញ្ជាដោយស្ងៀមស្ងាត់...។ បទភ្លេង «គោរពទង់បក្ស» ក៏បានបន្លឺឡើង រាំងននពណ៌ខៀវរបើកឡើង លេចផ្ទាំងកំណាត់ក្រហមទំហំប្រមាណ ៤ ម² មានសញ្ញាកណ្តៀវនិងញញួរប្រទាក់គ្នានៅចំកណ្តាលផ្ទាំងក្រហម។ ខ្ញុំងាកឆ្វេងស្តាំ ឃើញមិត្តជិតខាងក្តាប់ដៃគំនាប់យ៉ាងស្ងៀមស្ងាត់។ ខ្ញុំក៏ក្តាប់ដៃគំនាប់តាមគេដែរ ហើយងាកទៅខ្សឹបដាក់មិត្តខ្ញុំម្នាក់ដែលមានទស្សនៈនយោបាយដូចគ្នាជាភាសាបារាំងថា៖ «ដូចគេចាក់ចំបេះដូងខ្ញុំត្រូវមួយកាំបិត... ខ្ញុំមានអារម្មណ៍ហាក់ដូចរស់នៅក្នុងសហភាពសូវៀត»។ មិត្តខ្ញុំធ្វើសញ្ញាឲ្យខ្ញុំនិយាយតិចៗ កុំឲ្យគេឮ។ បន្តិចក្រោយមកឆ្លៀតពេលដែលអ្នកឯទៀតកំពុងចាប់អារម្មណ៍នឹងសុន្ទរកថារបស់អនុប្រធានភូមិភាគពិសេស យើងទាំងពីរនាក់កេះគ្នារំកិលខ្លួនបន្តិចម្តងៗ ចេញពីទីនោះទាំងចេងចោងស្រាលខ្លួន ព្រមទាំងអស់សង្ឃឹមថែមមួយត្រួតទៀត។ មិនដែលមានពេលណាដែលខ្ញុំអស់សង្ឃឹមនឹងរឿងជាតិដូចពេលនេះទេ...។

ការអប់រំនយោបាយតាមរយៈសន្និបាត ពេលធ្វើសន្និបាតម្តងៗ មានសន្និបាតបញ្ចៀវគ្គជាដើមវរជនខ្មែរក្រហម ឬកម្មាភិបាលរបស់គេតែងនាំគ្នាពិភាក្សាពីការលំបាក ឬការខ្វះខាតផ្សេងៗ ដែលគេបានជួបប្រទះក្នុងការអនុវត្តន៍មាគ៌ាបក្ស។

សន្និបាតរបស់គេមានលក្ខណៈចំហរខ្លះ សម្ងាត់ខ្លះ។ នៅក្នុងសន្និបាតជំហរ គេលើកបញ្ហានានាក្នុងក្របខ័ណ្ឌរណសិរ្សមកពិភាក្សា។ គេលាក់បំបាំងមិននិយាយពី «បក្សកុម្មុយនិស្ត» ពីកម្មវិធីនយោ-បាយរបស់បក្ស។

នៅក្នុងវង្វង់ «បក្ខជន» កុម្មុយនិស្ត ការពិភាក្សាផ្សេងៗ នៅក្នុងសន្និបាតមានលក្ខណៈជាសម្ងាត់ ព្រោះគេពិភាក្សាកម្មវិធីនយោបាយរបស់បក្សពិតប្រាកដ ពីយុទ្ធវិធី និងវិធីសាស្ត្របក្ស។ ក្រៅពីបក្ខជន ឬស្នូលសំខាន់ៗ គ្មានសមាជិកដទៃណាមានសិទ្ធិចូលរួមក្នុងមហាសន្និបាតនេះទេ។

## របៀបចាត់ចែងរដ្ឋាភិបាល ភូមិ ឃុំ ស្រុក តំបន់ ភាគ

*សព្វថ្ងៃនេះ ពួកខ្មែរក្រហមបានចែក ភូមិ ឃុំ ស្រុក ខេត្ត ភាគ ជា ភូមិ ឃុំ ស្រុក ខេត្ត ភាគ ដូចគ្នា។ ការបង្កើត តំបន់ ភាគ ដែលស្របទៅនឹង ខេត្ត ភាគ របស់យើង នៅពុំទាន់ច្បាស់លាស់នៅឡើយទេ តាមពិតតំបន់និមួយៗ របស់ខ្មែរក្រហម មានទំហំប៉ុននឹងរបស់យើង ហើយភាគនិមួយៗ ស្របគ្នានឹងភូមិភាគរដ្ឋរបស់យើង (Régions administratives)។*

*ភូមិ ឃុំ តំបន់ ភាគនិមួយៗ ដឹកនាំដោយគណៈកម្មការភូមិ ឃុំ ស្រុក តំបន់ ភាគ។ គេច្រើននិយាយដោយខ្លីថា គណៈភូមិ ឃុំ តំបន់។*

*គណៈកម្មការនិមួយៗ មានសមាសភាពដូចតទៅ :*

*-ប្រធាន*
*-អនុប្រធាន*
*-សមាជិក (ច្រើនឬតិច) ទទួលបន្ទុកខាងសេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌ យោធា ។ល។*

*ចំពោះឃុំ ស្រុក និងតំបន់ គេមានតែងតាំងស្នងការនយោបាយរបស់បក្សម្នាក់ ដែលគេនិយមហៅថា «លេខាបក្ស»(លេខារបស់បក្ស)។ «លេខាបក្ស» នេះមានអំណាចធំជាងគេ ព្រោះមានតំណាងរបស់បក្សសំរាប់តាមដានមើលសកម្មភាពរបស់គណៈកម្មការទាំងមូល។ នៅតាមឃុំដែលប្រជាជននៅពុំទាន់យល់ពីរឿងបដិវត្តន៍របស់គេ គេតែងតាំងឲ្យមានស្នងការនយោបាយរបស់បក្សម្នាក់ នៅអមគណៈកម្មការ។ ស្នងការនយោបាយ ឬ «លេខា» សុទ្ធតែជាបក្ខជន ជាសមាជិកពេញច្បាប់នៅក្នុងបក្ស។ ចំណែកសមាជិកឯទៀតនៃគណៈកម្មការ (លើកលែងគណៈតំបន់និងភាគ) មានខ្លះមិនទាន់បានចូលជាសមាជិកនៃបក្សទេ គឺគ្រាន់តែជា «ជនបង្គោល» ឬជាអ្នកធ្លាប់គាំទ្របដិវត្តន៍របស់គេជាយូរមកហើយ និងធ្លាប់បានទទួលការអប់រំនយោបាយជ្រៅជ្រះពីពួកគេ។ នៅមានប្រធាន ឬសមាជិកគណៈកម្មការរណសិរ្សភូមិឃុំខ្លះ នៅត្រឹមក្របខ័ណ្ឌរណសិរ្សនៅឡើយ គឺនៅយល់ថាគេធ្វើបដិវត្តន៍នេះដើម្បីប្រគល់អំណាចទៅឲ្យសីហនុវិញតែប៉ុណ្ណោះ។ ចំពោះសមាជិកគណៈកម្មការប្រភេទនេះ អង្គការខ្មែរក្រហមឃ្លាំមើលជានិច្ច ហើយគេឧស្សាហ៍អប់រំនយោបាយបន្តិចម្តងៗ ដើម្បីទាក់ទាញឲ្យលោតផ្លោះមកដល់លំដាប់បដិវត្តន៍សង្គមនិយម។*

*នៅចុងឆ្នាំ ១៩៧០ រហូតមកដល់ពាក់កណ្តាលឆ្នាំ ១៩៧១ សមាសភាពនៃគណៈកម្មការរណសិរ្សនៅតាមភូមិឃុំស្រុក នៅប្រឡូកប្រឡល់ខ្លាំងណាស់។ ពួកសីហនុនិយមបានទទួលតំណែងសំខាន់ៗជាច្រើន នៅក្នុងអង្គការក្រោម គឺនៅក្នុងគណៈភូមិ ឃុំ ស្រុក និងតំបន់ខ្លះៗ។ សមាជិកអស់នោះជ្រើសរើសឡើងទាំងបង្ខំដោយពួកយៀកកុង-យៀកណាមខាងជើង ម្ល៉ោះហើយច្រើនតែខ្វះការអប់រំខាងផ្នែកនយោបាយផ្សេងៗ ។ ចំណែកនៅអង្គការខាងលើ មានគណៈតំបន់ខ្លះ ខ្មែរក្រហមគេប្រកាន់នាទីជាប់មុខ គឺសមាជិកនៅក្នុងគណៈកម្មការដឹកនាំទាំងអស់ សុទ្ធតែជាសមាជិកពេញច្បាប់របស់បក្ស។ ដើម្បី*

ឲ្យបានចូលជាសមាជិកពេញច្បាប់របស់បក្ស ម្នាក់ៗ ត្រូវចូលបំរើចលនារបស់គេយ៉ាងតិចឲ្យបាន ២-៣ ឆ្នាំ ហើយត្រូវបំពេញលក្ខខ័ណ្ឌរបស់គេឲ្យបានគ្រប់សព្វផង។

ពួកខ្មែរក្រហមបានប្រើយុទ្ធវិធីនយោបាយមួយ ក្នុងការលេបកម្លាំងរណសិរ្សរបស់សីហនុ។ ដំបូង គឺនៅឆ្នាំ ១៩៧០ និង ១៩៧១ នៅពេលដែលកម្លាំងកុម្មុយនិស្តយៀកកុង-យៀកណាមខាងជើង កំពុងវាតត្បាតវាតទីខ្លាំង ទ័ពកុម្មុយនិស្តបរទេសក៏បានយកទុនប្រជាប្រិយស្តេចសីហនុមកធ្វើជាឡប់ឡែ ដើម្បីរកកម្លាំងបង្អែក កម្លាំងគាំទ្រនៅក្នុងស្រទាប់ប្រជាជនដែលពួកវាត្រួតត្រា។ ពេលនោះ កម្លាំងខ្មែរក្រហម ទាំងកម្លាំងយោធា ទាំងកម្លាំងនយោបាយនៅទន់ខ្សោយខ្លាំងណាស់។ ទាំងយៀកកុងយៀកណាមខាងជើង ទាំងពួកកុម្មុយនិស្តខ្មែរនាំគ្នាប្តូរវិធីនយោបាយគៀងគរកម្លាំងសីហនុនិយម ព្រោះនៅតាមតំបន់ជនបទភាគច្រើន ទុនប្រជាប្រិយភាពរបស់សីហនុនៅខ្លាំងនៅឡើយ។ ប្រជាកសិករ ពាណិជ្ជករមួយចំនួនធំនៅគាំទ្រស្តេចសីហនុ ជាហេតុនាំឲ្យអ្នកដឹកនាំខ្មែរក្រហមទៅពួនក្រោមឡប់ឡែ «រណសិរ្សរួបរួមជាតិកម្ពុជា»។ គណៈកម្មការកណ្តាលនៃបក្សកុម្មុយនិស្តខ្មែរ បានប្រទាញសីហនុឲ្យចូលអន្ទាក់របស់ខ្លួនតាមរយៈប៉េកាំង។ បានដៃហើយ ពួកខ្មែរក្រហមក៏ប្រើងចំហៀវខ្ទាញ់សីហនុឲ្យអស់ពីខ្លួន។

សព្វថ្ងៃនេះ កម្លាំងរណសិរ្សរបស់សីហនុបានក្លាយទៅជាកម្លាំងនយោបាយរបស់បក្សកុម្មុយ-និស្តខ្មែរទៅវិញហើយ។ ពួកក្របខ័ណ្ឌខ្មែរក្រហម ទាំងក្របខ័ណ្ឌនយោបាយ ទាំងក្របខ័ណ្ឌយោធាបានចូលកាន់កាប់គ្រប់អង្គការតូចធំរបស់រណសិរ្សជំនួសពួកសីហនុនិយមអស់ហើយ។ ពួកសីហនុនិយមទាំងអម្បាលមាណបានប្រែក្លាយទៅជាខ្មែរក្រហម។ សព្វថ្ងៃនេះ ចាប់តាំងពីពួកខ្មែរក្រហមចាប់បើកមុខបង្ហាញដល់សាធារណជនមក ពួកក្របខ័ណ្ឌខ្មែរក្រហមចាប់ធ្វើការអប់រំទ្រឹស្តីសង្គមនិយមយ៉ាងសកម្ម។

អំណោះតទៅ នៅក្នុងបញ្ហាខ្មែរ ខ្មោចរាជានិយមក្តី ខ្មោចសីហនុក្តី អស់មានឥទ្ធិពលមកលងទៀតហើយ។ កងប្រវត្តិសាស្ត្របានវិលទៅមុខគ្មានត្រឡប់។ មានតែកម្លាំងនយោបាយពីរទេ ដែលត្រូវប្រឈមមុខដាក់គ្នាទៅវិញទៅមក គឺរបបសាធារណរដ្ឋខ្មែរសេរី និងកម្លាំងកុម្មុយនិស្ត។

នៅក្នុងចំបាំងទប់ទល់នឹងកុម្មុយនិស្តឥណ្ឌូចិនសព្វថ្ងៃនេះ ប្រជាជាតិខ្មែរត្រូវការសេរីវើរៀបចំជំហរជាតិមួយថ្មីជាចាំបាច់ដែលជាដំណាក់ការទី២ នៃបដិវត្តន៍ ១៨ មីនា ដើម្បីយើងមានលទ្ធភាពខ្លួនឯងទប់ទល់នឹងកម្លាំងស្រូបនៃបដិវត្តន៍កុម្មុយនិស្តនៅភូមិភាគឥណ្ឌូចិននេះ។ ដើម្បីចៀសវាងកុំឲ្យវាសនាខ្មែរក្លាយទៅជាវាសនានៃរដ្ឋប៉ូឡូញ គួរតែពួកឆ្វេងនិយមខ្មែរបោះបង់ចោលគំនិតវើរវាយក្នុងផ្លូវនយោបាយ ហើយមកជួយរៀបចំសង្គមជាតិ ឆ្ពោះទៅរកវឌ្ឍនធម៌និងសុភមង្គលតាមរបៀបខ្មែរ ក្នុងវង្វង់គ្រួសារខ្មែរគ្នាឯង ព្រោះមានតែរបបខ្មែរទេដែលតំណាងឆន្ទៈប្រជាជាតិខ្មែរពិតប្រាកដ ហើយរបបខ្មែរនោះឯង ក៏ជាសំយោគនៃរបបមូលធននិយម និងរបបសង្គមនិយមស្រេចបាច់មកហើយផង។

**ចប់**